

# សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ៖ ទស្សនៈរបស់ភ្ញៀវទេសចរ

របាយការណ៍ផលិតដោយគម្រោងកុមារភាព ផ្នែកបង្ការ

Australian Aid

World Vision

សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ៖ ទស្សនៈរបស់ភ្ញៀវទេសចរ

ISBN: ៩៧៨-០-៩៨៧៤៤៤១-៣-៤

រក្សាសិទ្ធិ © ឆ្នាំ២០១៣ ដោយអង្គការទស្សនៈពិភពលោកប្រចាំប្រទេសអូស្ត្រាលី

គ្រប់ផ្នែកនៃឯកសារនេះអាចត្រូវបានផលិតឡើងវិញដោយសេរី ដោយមានការទទួលស្គាល់ប្រភពឯកសារបានសមស្រប។

www.childsafetourism.org

childsafetourism@wvi.org

សម្របសម្រួលការស្រាវជ្រាវដោយ Afrooz Kaviani Johnson និង Aarti Kapoor គម្រោងកុមារភាព ផ្នែកបង្ការ នៃអង្គការទស្សនៈពិភពលោក។ សរសេររបាយការណ៍ដោយបណ្ឌិត Amie Matthews និងត្រួតពិនិត្យដោយ Afrooz Kaviani Johnson និង Aarti Kapoor។ រចនាដោយ Juan Miguel Lago។

រូបថតដោយ ៖ អង្គការទស្សនៈពិភពលោក/Thongxay Phavixay, Albert Yu, Xuan Thiem Le, Sopheak Kong

គម្រោងកុមារភាព ផ្នែកបង្ការ គឺជាគំនិតផ្តួចផ្តើមមួយរបស់ក្រសួងការបរទេស និងពាណិជ្ជកម្ម កម្មវិធីជំនួយអូស្ត្រាលី (DFAT)។ ទស្សនៈដែលបង្ហាញនៅក្នុងឯកសារនេះជាទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងទាំងស្រុងពីទស្សនៈនៃរដ្ឋាភិបាលអូស្ត្រាលី ឬទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិឡើយ។



# សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ៖ ទស្សនៈរបស់ភ្ញៀវទេសចរ

របាយការណ៍ផលិតដោយគម្រោងកុមារភាព ផ្នែកបង្ការ



# មាតិកា

មូលសង្ខេប ២
សាវតានៃការសិក្សា ៤
ឧបសគ្គ និងភាពមានកម្រិតនៃទិន្នន័យ ៨
អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិស្ដីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ៨
តើអ្នកចូលរួមទាំងនេះធ្វើដំណើរទៅណា និងដើម្បីអ្វី ? ៩
ប្រភេទ និងបែបបទនៃការធ្វើដំណើរ ១១
ការរៀបផែនការធ្វើដំណើរ និងការចូលរួមជាមួយប្រព័ន្ធផ្សព្វផ្សាយផ្នែកធ្វើដំណើរ ១២
ការសង្កេតលើកុមារ និងការប្រាស្រ័យទាក់ទងនឹងកុមារនៅក្នុងតំបន់ ១៣
ការជួបប្រទះកុមារសុំទាន ឬលក់អីវ៉ាន់ ១៦
ការជួបប្រទះការកេងប្រវ័ញ្ច/រំលោភបំពានលើកុមារនៅពេលធ្វើដំណើរ ១៩
ការយល់ឃើញ និងចំណាប់អារម្មណ៍របស់ភ្ញៀវទេសចរចំពោះ "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ២៤
សេចក្ដីសន្និដ្ឋានបញ្ចប់ ២៦
អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ថែមទៀត ៣០
ឧបសម្ព័ន្ធ៖ កំរងសំណួរ ៣៣

# មូលសង្ខេប

របាយការណ៍នេះ សង្ខេបនូវលទ្ធផលនៃការស្ទាបស្ទង់មតិតាមអ៊ីនធឺណេតដែលធ្វើឡើងចំពោះអ្នកដំណើរអន្តរជាតិជាង៣០០នាក់ ដែលមកកាន់ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម (នៅក្នុងរបាយការណ៍នេះ ប្រទេសទាំងនេះរួមគ្នាមកត្រូវបានហៅថា "តំបន់" )។ ការស្ទាបស្ទង់មតិនេះធ្វើឡើងដើម្បីស្វែងយល់ពីអន្តរសកម្មភាពដែលភ្ញៀវទេសចរមានជាមួយកុមារនៃប្រទេសទាំងនេះក៏ដូចជាដើម្បីវាស់ស្ទង់ពីការយល់ឃើញចំពោះអន្តរសកម្មភាពទាំងនេះ និងចំពោះសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ក្នុងទិដ្ឋភាពជារួម។ លទ្ធផលនៃការស្ទាបស្ទង់មតិនេះបង្ហាញថា ៖[1]

**ជារឿយៗ ភ្ញៀវទេសចរប្រាស្រ័យទាក់ទងជាមួយកុមារក្នុងស្រុកនៅពេលពួកគេមកទស្សនាតំបន់នេះ និងរីករាយចំពោះទំនាក់ទំនងនេះ។** បើទោះជាអន្តរសកម្មភាពបែបនេះអាចជាបទពិសោធន៍វិជ្ជមានសម្រាប់ភ្ញៀវទេសចរ ក៏វាអាចបន្សល់ទុកនូវចំណាប់អារម្មណ៍អវិជ្ជមានរយៈពេលយូរនៅក្នុងទឹកចិត្តរបស់អ្នកដំណើរបានដែរ។ ឧទាហរណ៍ ការជួបជាមួយកុមារម្ចាស់ស្រុកត្រូវបានពណ៌នាបែបវិជ្ជមាន ដោយអ្នកដំណើរដែលបង្ហាញថាពួកគេបានយល់ដឹងពីលក្ខណពិសេសនៃប្រទេសនេះ ឬវប្បធម៌ម្ចាស់ស្រុកតាមរយៈកុមារដែលពួកគេបានជួប ដោយអ្នកដំណើរដែលចូលចិត្តនិយាយ និងលេងកំសាន្តជាមួយកុមារម្ចាស់ស្រុក ឬដោយអ្នកដំណើរដែលយល់ថាកុមារម្ចាស់ស្រុកមានភាពរួសរាយរាក់ទាក់។ ផ្ទុយទៅវិញ នៅពេលជួបជាមួយកុមារម្ចាស់ស្រុកដែលមានជីវភាពក្រីក្រ និងងាយរងគ្រោះ ឬកុមារដែលគេមើលឃើញថារស់នៅក្នុងបរិបទកាន់តែធំទូលាយនៃការរំលោភបំពាន ឬកេងប្រវ័ញ្ចអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិជាទូទៅពណ៌នាពីបទពិសោធន៍ទាំងនេះបែបអវិជ្ជមាន។ បទពិសោធន៍បែបនេះមិនត្រឹមតែប៉ះពាល់ដល់អារម្មណ៍ភ្ញៀវទេសចរប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងករណីជាច្រើន បទពិសោធន៍ទាំងនេះក៏ប៉ះពាល់ដល់ការយល់ឃើញរបស់ភ្ញៀវទេសចរចំពោះវប្បធម៌ និងកន្លែងគោលដៅទេសចរណ៍ផងដែរ។

**លើសពីពាក់កណ្តាល( ៥៧,១% ) នៃអ្នកចូលរួមបង្ហាញថាពួកគេបានឃើញស្ថានភាពដែលទាក់ទងនឹងការកេងប្រវ័ញ្ច ឬរំលោភបំពានលើកុមារ ក្នុងពេលធ្វើដំណើរនៅក្នុងតំបន់នេះ។** អ្នកឆ្លើយតបពណ៌នាស្ថានភាពដែលពួកគេបានឃើញកុមារលក់ទំនិញ ឬសុំទាន ឬត្រូវបានប្រើប្រាស់ដោយមនុស្សពេញវ័យ ( ក្នុងករណីខ្លះ គឺត្រូវបានប្រើប្រាស់ដោយម្តាយឪពុករបស់កុមារទាំងនោះ ) ឲ្យដើរតួធ្វើយ៉ាងណាឲ្យភ្ញៀវទេសចរអាណិតពួកគេ។ ភ្ញៀវទេសចរទាំងនោះក៏សម្តែងនូវកង្វល់ផងដែរលើបញ្ហាកុមារមិនទៅសាលារៀន ត្រូវបានបង្ខំឲ្យសម្តែងសិល្បៈជូនភ្ញៀវទេសចរទស្សនា និងកុមារដែលរងការកេងប្រវ័ញ្ចផ្លូវភេទ។

**៨៥% នៃអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះ រាយការណ៍ថាបានជួបមនុស្សវ័យក្មេងព្យាយាមលក់វត្ថុអនុស្សាវរីយ៍ឲ្យពួកគេ ហើយ៨១,២% រាយការណ៍ថាបានជួបកុមារ ឬមនុស្សវ័យក្មេង (អាយុក្រោម ១៨ឆ្នាំ ) ព្យាយាមសុំទានពីពួកគេ។** អ្នកចូលរួមការស្ទាបស្ទង់មតិភាគច្រើនក៏រាយការណ៍ថាបានឃើញកុមារដើររើសសំរាម( ៤៩% ) ធ្វើការតាមភោជនីយដ្ឋាន ឬសណ្ឋាគារ( ៤៨,៥% ) និងសម្តែងសិល្បៈតាមចិញ្ចើមថ្នល់( ៣៨% )។

អ្នកចូលរួមមួយចំនួនក៏អះអាងថាពួកគេបានឃើញកុមារ និងមនុស្សវ័យក្មេងធ្វើការជាអ្នក

1 លក្ខណៈនៃប្រធានបទស្ទាបស្ទង់មតិ និងឧបករណ៍ស្ទាបស្ទង់មតិធ្វើឲ្យលទ្ធផលមួយចំនួនឆ្លុះបញ្ចាំងពីការយល់ឃើញរបស់អ្នកឆ្លើយតបជាជាងស្ថានភាពជាក់ស្តែងនៃកុមារនៅតាមកន្លែងគោលដៅទេសចរណ៍នៅក្នុងតំបន់នេះ។

មគ្គុទ្ទេសក៍ទេសចរ (២៥,៥%) និងកាន់តែគួរឲ្យបារម្ភបំផុត គឺធ្វើការក្នុងរបររកស៊ីផ្លូវភេទ (២០,៥%)។ គួរឲ្យចាប់អារម្មណ៍ជាខ្លាំង គ្រប់អ្នកចូលរួមដែលបានឃើញប្រភេទនៃការកេងប្រវ័ញ្ចទាំងនេះ លើកឡើងថាវាធ្វើឲ្យពួកគេមានអារម្មណ៍ខ្ពើមរអើម ក្រៀមក្រំ មានក្ដីកង្វល់ ឬព្រួយបារម្ភ មិនដឹងថាជួយយ៉ាងណា បន្ទោសខ្លួនឯង ខឹង និង/ឬអន្ទះសារ។

**២៨%នៃអ្នកចម្លើយតបបង្ហាញថាពួកគេគិតថាការរួមផ្សំគ្នានៃឥរិយាបថកេងប្រវ័ញ្ចទាំងនេះអាចបណ្ដាលមកពីប្រជាជនក្នុងស្រុកចាត់ទុកវាថាជារឿងធម្មតា ឬមកពីប្រជាជនក្នុងស្រុក (រួមទាំងអាជ្ញាធរមូលដ្ឋាន) មិនអើពើយកភ្នែកមើលតែម្ដង។** ការយល់ឃើញនេះផ្ដល់នូវក្ដីព្រួយបារម្ភដោយមូលហេតុជាច្រើន។ ទីមួយ វាកំណត់នូវស្ដង់ដារដ៏ទាបនៃទស្សនៈដែលភ្ញៀវទេសចរគិតថាខ្លួនត្រូវប្រព្រឹត្ត ហើយអាចប៉ះពាល់ដល់ឆន្ទៈនៃអ្នកដំណើរក្នុងការចូលរួម ឬធ្វើអន្តរាគមន៍ក្នុងករណីសង្ស័យថាមានការកេងប្រវ័ញ្ច/រំលោភបំពានលើកុមារ។ ម្យ៉ាងវិញទៀត គំនិតដែលថាសហគមន៍មិនប្រកាន់ ឬព្រមទទួលយកការរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារ គឺជាកេរ្ដិ៍ឈ្មោះអាក្រក់សម្រាប់គោលដៅទេសចរណ៍ ដែលបំផ្លាញយ៉ាងខ្លាំងដល់ឧស្សាហកម្មទេសចរណ៍។

**ការរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារក្នុងវិស័យទេសចរណ៍ មិនត្រូវបានភ្ញៀវទេសចរអត់ឱនឲ្យនោះឡើយ ហើយវាអាចប៉ះពាល់ជាខ្លាំងដល់កេរ្ដិ៍ឈ្មោះនៃគោលដៅទេសចរណ៍សម្រាប់ភ្ញៀវទេសចរ (និងអ្នកដែលអាចជាភ្ញៀវទេសចរ)។** អ្នកចូលរួមជាច្រើនក្នុងការស្ទាបស្ទង់មតិនេះរាយការណ៍ថាបានប្រាប់មិត្តភក្ដិ គ្រួសារ និងអ្នករួមការងារនៅក្នុងប្រទេសរបស់ពួកគេ ពីកង្វល់របស់ពួកគេចំពោះកុមារនៅក្នុងតំបន់នេះដែលរងការកេងប្រវ័ញ្ច ឬរំលោភបំពាន។ អ្នកឆ្លើយតបមួយចំនួនក៏បង្ហាញថាពួកគេបានកាត់បន្ថយរយៈពេលទស្សនាទីកន្លែងជាក់លាក់ណាមួយ ឬមិនត្រឡប់ទៅគោលដៅទេសចរណ៍មួយចំនួន ដោយសារពួកគេបានឃើញហេតុការណ៍ដែលពួកគេគិតថាពាក់ព័ន្ធនឹងការរំលោភបំពានលើកុមារ និងមនុស្សវ័យក្មេង។ ហេតុនេះហើយ ដើម្បីជាប្រយោជន៍ដល់ឧស្សាហកម្មទេសចរណ៍អាជ្ញាធរ និងរដ្ឋាភិបាល ក៏ដូចជាអ្នកផ្ដល់សេវាផ្នែកទេសចរណ៍ ត្រូវបន្ដដោះស្រាយបញ្ហាទាំងនេះ និងធានាថាកុមារទទួលបានការពារពីការរំលោភបំពានគ្រប់រូបភាពក្នុងវិស័យទេសចរណ៍ក្នុងតំបន់នេះ។

**៨៣% នៃអ្នកចូលរួម លើកឡើងថាពួកគេមិនទិញទំនិញ/សេវាកម្មពីកុមារ ហើយ ៧៨,៧% លើកឡើងថាពួកគេមិនឲ្យលុយដល់កុមារ ឬមនុស្សវ័យក្មេងសុំទាន។** ប្រការនេះបង្ហាញថាភ្ញៀវទេសចរដែលចូលរួមក្នុងការស្ទាបស្ទង់មតិនេះ បង្ហាញនូវកម្រិតយល់ដឹងសមស្របចំពោះបញ្ហាទាក់ទងនឹងកុមារលក់ទំនិញឲ្យភ្ញៀវទេសចរ ឬសុំទាន។ ភាគច្រើនមានការលើកឡើងពីមូលហេតុនៃការចៀសវាងទំនាក់ទំនងបែបនេះជាមួយមនុស្សវ័យក្មេង គឺដើម្បីបង្អាក់ទឹកចិត្តចំពោះវប្បធម៌សង្គមសេដ្ឋកិច្ចដែលគ្មាននិរន្តរភាពកុំឲ្យបន្តកើតមានតទៅទៀត និងដើម្បីបញ្ចៀសការដាក់កុមារ ឬមនុស្សវ័យក្មេងទៅក្នុងស្ថានភាព "ប្រឈមនឹងហានិភ័យ"។ អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះភាគច្រើនមានការយល់ដឹងខ្ពស់អំពីចំណុចដែលថា បើកុមារនៅដើរសុំទានតាមចិញ្ចើមផ្លូវ និង/ឬលក់អីវ៉ាន់ នោះពួកគេច្រើនតែមិនអាចទៅរៀននោះទេ និងអាចងាយរងគ្រោះពីការកេងប្រវ័ញ្ច ឬរំលោភបំពាន។ អ្នកចូលរួមភាគច្រើនក៏និយាយដែរថាការសុំទានមិនមែនជាមធ្យោបាយល្អសម្រាប់បញ្ចប់វដ្ដនៃភាពក្រីក្រនោះឡើយ។

បើប្រៀបធៀបមើលទៅ អ្នកចូលរួមភាគច្រើនក៏បានលើកឡើងពីចំណុចដែលពួកគេគិតថាជាជម្រើសដែលប្រសើរជាងនេះដូចជាការបរិច្ចាគលុយដល់អង្គការសប្បុរសធម៌ក្នុងស្រុក ឬឲ្យអាហារដល់កុមារវិញ។

**ស្ទើរពាក់កណ្តាល (៤៩,៥%) នៃអ្នកឆ្លើយតប យល់ថាពួកគេត្រូវចូលរួមទទួលខុសត្រូវចំពោះកុមារ និងមនុស្សវ័យក្មេងក្នុងស្រុក នៅពេលធ្វើដំណើរ។** អ្នកចូលរួមមួយចំនួនហាក់ដូចជាមានយុទ្ធសាស្រ្តច្បាស់លាស់សម្រាប់ដោះស្រាយជាមួយកុមារដែលដើរសុំទាន ឬលក់ទំនិញនិងសេវាកម្មក្នុងតំបន់នេះ ហើយអ្នកចូលរួមភាគច្រើនបានព្យាយាមជាខ្លាំងដើម្បីធានាថាអន្តរសកម្មភាពរបស់ពួកគេជាមួយកុមារមានលក្ខណៈប្រកបដោយសីលធម៌។ អ្នកចូលរួមមួយចំនួនរាយការណ៍ថាបានអនុវត្តជំហានសកម្មដើម្បីជួយកុមារដែលត្រូវការការជួយ ហើយអ្នកឆ្លើយតបភាគច្រើនបង្ហាញថាពួកគេពិតជាចង់ជួយកុមារនៅពេលដែលពួកគេស្នាក់នៅក្នុងតំបន់នេះ។ ទោះជាយ៉ាងណាក៏ដោយ ក៏សូម្បីតែអ្នកចូលរួមដែលព្យាយាមជាខ្លាំងក្នុងការជួយប្រជាជនក្នុងស្រុក (និងជាពិសេសគឺជួយកុមារ) ហាក់ដូចជាស្រពេចស្រពិលមិនដឹងថាសកម្មភាពរបស់ពួកគេគឺជាការអនុវត្តល្អបំផុតដែរឬយ៉ាងណានោះទេ។ មានការលើកឡើងពីមន្ទិល និងភាពស្រពេចស្រពិលដែលឧស្សាហ៍កើតមានស្តីពីវិធីដ៏ល្អបំផុតក្នុងការប្រាស្រ័យទាក់ទងជាមួយកុមារនៅក្នុងតំបន់នេះ។

**ត្រឹមតែ១៩,៥%នៃអ្នកឆ្លើយតបចំពោះការស្ទាបស្ទង់មតិនេះប៉ុណ្ណោះ ដែលយល់ថាពួកគេមានព័ត៌មានគ្រប់គ្រាន់ដើម្បីការពារកុមារ និងមនុស្សវ័យក្មេងម្ចាស់ស្រុកដែលពួកគេបានជួបនៅកន្លែងសាធារណៈ។** ក៏ប៉ុន្តែ គួរឲ្យចាប់អារម្មណ៍ជាខ្លាំង អ្នកចូលរួមភាគច្រើនបង្ហាញថាពួកគេចង់ដឹងបន្ថែមពីស្ថានភាព និងរបៀបដែលពួកគេអាចជួយកុមារទាំងនោះ។

**៨៨,៨%នៃអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះ លើកឡើងថាពួកគេចង់ដឹងបន្ថែមពីរបៀបការពារកុមារ និងទប់ស្កាត់ការកេងប្រវ័ញ្ចលើកុមារនៅក្នុងតំបន់នេះ។** អ្នកចូលរួមក្នុងចំនួនប្រហាក់ប្រហែលគ្នានេះដែរនិយាយថាពួកគេចង់ដឹងបន្ថែមពីប្រពៃណីក្នុងស្រុក សម្លៀកបំពាក់ និងឥរិយាបថសមស្រប (៨៣,៣%) និងពីរបៀបដែលភ្ញៀវទេសចរអាចគាំទ្រដល់សេដ្ឋកិច្ចក្នុងស្រុក (៨៣%)។ ដូចគ្នានេះដែរ នៅពេលសួរថាតើគោលនយោបាយនៃអាជីវកម្មដែលការពារកុមារនឹងជះឥទ្ធិពលលើទម្លាប់ទិញរបស់ពួកគេឬទេ ៩៤,៨% នៃអ្នកចូលរួមបាននិយាយថា វាពិតជានឹងជះឥទ្ធិពលលើទម្លាប់ទិញរបស់ពួកគេ។

# សាវតានៃការសិក្សា

ក្នុងនាមជាឧស្សាហកម្មធំជាងគេមួយលើពិភពលោក វិស័យទេសចរណ៍មានឥទ្ធិពលសេដ្ឋកិច្ចយ៉ាងសំខាន់លើតំបន់អាស៊ីអាគ្នេយ៍ជាពិសេសសម្រាប់សេដ្ឋកិច្ចនៃប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ដែលអត្រាមកទស្សនារបស់ភ្ញៀវទេសចរបានកំពុងកើនឡើងជាទ្វេគុណក្នុងទសវត្សចុងក្រោយនេះ។ ក្នុងឆ្នាំ ២០១១ ប្រទេសកម្ពុជាទទួលបានភ្ញៀវទេសចរច្រើនជាង ២,៨លាននាក់ ត្រូវជាកំណើន ១៥% បើធៀបនឹងចំនួនកត់ត្រាក្នុងឆ្នាំ ២០១០។ ជាលទ្ធផល ក្នុងឆ្នាំដដែល វិស័យទេសចរផ្តល់ថវិកាចំណូលសរុបប្រមាណ ១.៩១២ លានដុល្លាសហរដ្ឋអាមេរិក។[2] ស្រដៀងគ្នានេះដែរ ចំនួនភ្ញៀវទេសចរដែលមក

2 ទិន្នន័យបានមកពីរាជរដ្ឋាភិបាលកម្ពុជា (២០១២)។ បទបង្ហាញនៅគណៈកម្មាធិការសម្របសម្រួលនៃគម្រោងកុមារភាព ទីក្រុងបាំងកក ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២។

ទស្សនាប្រទេសឡាវបានបន្តកើនឡើងពីឆ្នាំ ១៩៩០-២០១០ ជាមួយអត្រាកំណើនជាមធ្យម ២០,៦៧%។[3]

ក្នុងឆ្នាំ២០១១ ប្រទេសឡាវទទួលបានភ្ញៀវទេសចរច្រើនជាង២,៧លាននាក់ ត្រូវជាកំណើន ៨% លើសឆ្នាំ ២០១០។[4] រីឯប្រទេសថៃក៏មានការកើនឡើងស្របគ្នានេះដែរ ដោយទទួលបានភ្ញៀវទេសចរជាង ១៩ លាននាក់ក្នុងឆ្នាំ ២០១១ ត្រូវជាកំណើន ១៩,៨៤% បើធៀបនឹងចំនួនក្នុងឆ្នាំ ២០១០។ ភ្ញៀវទេសចរភាគច្រើនជាងគេដែលមកទស្សនាប្រទេសថៃរួមមានជនជាតិម៉ាឡេស៊ី ចិន និងជប៉ុន ហើយវិស័យទេសចរផ្តល់ថវិកាចំណូលសរុបប្រមាណ២៣ពាន់លានដុល្លារសហរដ្ឋអាមេរិក ត្រូវជាកំណើន ២៣,៩២% លើសឆ្នាំ ២០១០។[5] ជាចុងក្រោយក្នុងឆ្នាំ ២០១១ ប្រទេសវៀតណាមទទួលបានភ្ញៀវទេសចរច្រើនជាង ៦លាននាក់ ត្រូវជាកំណើន ១៩,១% លើសឆ្នាំ ២០១០។ ភ្ញៀវទេសចរភាគច្រើនជាងគេដែលមកទស្សនាប្រទេសវៀតណាមរួមមានជនជាតិចិន សហរដ្ឋអាមេរិក និងកូរ៉េខាងត្បូង។[6]

កំណើននេះពិតជាផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ច ហើយហេតុនេះជារឿយៗ វាត្រូវបានស្វាគមន៍ដោយមន្ត្រីរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ និងសហគមន៍ក្នុងស្រុក។ បើតាមក្រុមប្រឹក្សាធ្វើដំណើរ និងទេសចរណ៍ពិភពលោក ក្នុងឆ្នាំ ២០១១ វិស័យទេសចរណ៍តំណាងឲ្យ៩,៥%នៃផលិតផលក្នុងស្រុកសរុប ("ផសស") របស់ប្រទេសកម្ពុជា និងតំណាងឲ្យ៥,៨%នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសឡាវ (បើធំជាង "មានឥទ្ធិពល" ឬ "ប្រយោល" ដែលកាន់តែធំនៃវិស័យទេសចរណ៍នោះ ការរួមចំណែកនេះនឹងកាន់តែខ្ពស់ ពោលគឺ ២២,១%សម្រាប់ប្រទេសកម្ពុជា និង១៨,២% សម្រាប់ប្រទេសឡាវ)។[7]

ស្រដៀងគ្នានេះដែរ វិស័យទេសចរណ៍តំណាងឲ្យ ៧,១% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសថៃ និងតំណាងឲ្យ ៤,៣% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសវៀតណាម។[8]

គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ ប្រការនេះមានន័យថាវិស័យទេសចរណ៍រួមចំណែក យ៉ាងសំខាន់ដល់ភាពមានការងារធ្វើនៅក្នុងប្រទេសទាំងនេះ។ ក្នុងឆ្នាំ ២០១១ ការងារចំនួន ៦០៧.០០០ កន្លែង (៨,០% នៃការងារសរុប)ក្នុងប្រទេសកម្ពុជាគឺបានផ្ទាល់មកពីវិស័យទេសចរណ៍និងធ្វើដំណើរ ហើយនៅក្នុងប្រទេសឡាវ វិស័យទេសចរណ៍ រួមចំណែកដោយផ្ទាល់នូវ ៤,៩% នៃការងារសរុប (ត្រូវជា ១៤៣.៥០០កន្លែង)។ ក្នុងប្រទេសថៃ "វិស័យទេសចរណ៍និងធ្វើដំណើរ ផ្តល់ការងារដោយផ្ទាល់ចំនួន១.៨៣៣.០០០ កន្លែង" (ត្រូវជា៤,៧%នៃការងារសរុប) ហើយក្នុងប្រទេសវៀតណាម

---

3 ទិន្នន័យនៅក្នុងផ្នែកនេះបានមកពីរដ្ឋបាលវិស័យទេសចរណ៍ជាតិឡាវ (២០១០) របាយការណ៍ស្ថិតិឆ្នាំ២០១០ស្តីពីវិស័យទេសចរណ៍ក្នុងប្រទេសឡាវ នាយកដ្ឋានផែនការ និងសហប្រតិបត្តិការ អង្គភាពស្ថិតិវិស័យទេសចរណ៍។

4 ទិន្នន័យបានមកពីសាធារណរដ្ឋប្រជាធិប្បតេយ្យប្រជាមានិតឡាវ (២០១២)។ បទបង្ហាញនៅគណៈកម្មាធិការសម្របសម្រួលនៃគម្រោងកុមារភាព ទីក្រុងបាំងកក ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២។

5 ទិន្នន័យបានមកពីរាជរដ្ឋាភិបាលថៃ (២០១២)។ បទបង្ហាញនៅគណៈកម្មាធិការសម្របសម្រួលនៃគម្រោងកុមារភាព ទីក្រុងបាំងកក ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២។

6 ទិន្នន័យបានមកពីរាជរដ្ឋាភិបាលវៀតណាម (២០១២)។ បទបង្ហាញនៅគណៈកម្មាធិការសម្របសម្រួលនៃគម្រោងកុមារភាព ទីក្រុងបាំងកក ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២។

7 ក្រុមប្រឹក្សាធ្វើដំណើរ និងទេសចរណ៍ពិភពលោក (២០១២) ឥទ្ធិពលសេដ្ឋកិច្ចនៃវិស័យទេសចរណ៍និងធ្វើដំណើរ៖ កម្ពុជា និងក្រុមប្រឹក្សាធ្វើដំណើរ និងទេសចរណ៍ពិភពលោក (២០១២) ឥទ្ធិពលសេដ្ឋកិច្ចនៃវិស័យទេសចរណ៍និងធ្វើដំណើរ៖ ឡាវ លើគេហទំព័រ www.wttc.org/research/ ចូលមើលនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២

8 សម្រាប់ព័ត៌មានបន្ថែម សូមមើលក្រុមប្រឹក្សាធ្វើដំណើរ និងទេសចរណ៍ពិភពលោក (២០១២) ឥទ្ធិពលសេដ្ឋកិច្ចនៃវិស័យធ្វើដំណើរ និងទេសចរណ៍៖ ថៃ និងក្រុមប្រឹក្សាទេសចរណ៍និងធ្វើដំណើរ ពិភពលោក (២០១២) ឥទ្ធិពលសេដ្ឋកិច្ចនៃវិស័យទេសចរណ៍និងធ្វើដំណើរ ៖ វៀតណាម លើគេហទំព័រ www.wttc.org/research/ ចូលមើលនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២

វិស័យទេសចរណ៍ផ្តល់នូវការងារចំនួន ១.៨៣២.៥០០កន្លែង (ត្រូវជា ៣,៧% នៃការងារសរុប)។ នៅក្នុងប្រទេសនីមួយៗនៃប្រទេសទាំងនេះ មានការរំពឹងថាការរួមចំណែកសេដ្ឋកិច្ចនៃវិស័យទេសចរណ៍ (រួមបញ្ចូលទាំងភាពមានការងារធ្វើ) នឹងបន្តកើនឡើងនាពេលអនាគត។[9]

បើទោះជាគេមិនត្រូវមើលរំលងនូវសារៈសំខាន់នៃការរួមចំណែកសេដ្ឋកិច្ចទាំងនេះ ក៏មានការចងក្រងឯកសារយ៉ាងប្រសើ ខណៈដែលវិស័យទេសចរណ៍បានរួមចំណែកយ៉ាងវិជ្ជមាន គួរឲ្យកត់សម្គាល់ដល់ប្រទេសម្ចាស់ផ្ទះ ក៏វិស័យនេះអាចនាំមកនូវបញ្ហាសង្គម វប្បធម៌ និងបរិស្ថានគួរឲ្យកត់សម្គាល់ និងមានរយៈពេលយូរ។ បញ្ហាទាំងនេះត្រូវបានពង្រីកបន្ថែមនៅក្នុងបរិបទដែលមានការអភិវឌ្ឍវិស័យទេសចរណ៍យ៉ាងលឿន ហើយដែលជារឿយៗមានលក្ខណៈមិនបានរៀបផែនការទុក ឬគ្រប់គ្រងឲ្យបានល្អ។ កង្វល់មួយសម្រាប់គម្រោងកុមារភាព ផ្ទែកបង្ការ គឺរបៀបដែលវិស័យទេសចរណ៍ជះឥទ្ធិពល (ដែលនឹងរៀបរាប់លម្អិតនៅផ្នែកខាងក្រោម) ទៅលើជីវិតរបស់កុមារ។ ដោយសារកត្តាអូសទាញផ្នែកសេដ្ឋកិច្ចនៃវិស័យទេសចរណ៍ គេឃើញមានទំនាក់ទំនងយ៉ាងច្បាស់លាស់រវាងវិស័យទេសចរណ៍ និងការកេងប្រវ័ញ្ចលើកុមារ។ កុមារងាយរងគ្រោះ និងគ្រួសាររបស់ពួកគេតែងតែត្រូវបានអូសទាញឲ្យធ្វើការនៅគោលដៅទេសចរណ៍ក្នុងគោលបំណងដើម្បីស្វែងរកប្រាក់ចំណូល។ ប្រការនេះអាចមានន័យថាត្រូវបោះបង់ជីវភាពតាមបែបប្រពៃណី ចំណងទាក់ទងក្នុងសហគមន៍ និង/ឬបណ្តាញគាំទ្រផ្នែកសង្គម។ វាក៏អាចមានន័យថាកុមារីនិងកុមារាត្រូវធ្វើការក្នុងឧស្សាហកម្មទេសចរណ៍ក្នុងលក្ខខណ្ឌដែលគ្មានសុវត្ថិភាព ឬមានគ្រោះថ្នាក់។ លើសពីនេះទៅទៀត កុមារដែលរកប្រាក់ចំណូលពីភ្ញៀវទេសចរក្នុងទម្រង់ជាច្រើន មិនសូវបានទៅសាលារៀន និងប្រឈមខ្លាំងនឹងភាពងាយរងគ្រោះពីទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ច រួមបញ្ចូលទាំងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ។ ដោយសារតែយន្តការការពារដែលនៅក្បែរកុមារទាំងនេះនៅមានកម្រិតទាប នោះពួកគេងាយនឹងក្លាយជាគោលដៅនៃអ្នករំលោភបំពានលើកុមារ រួមបញ្ចូលទាំងជនល្មើសដែលធ្វើដំណើរទៅកន្លែងផ្សេងៗដើម្បីធ្វើការរំលោភបំពានផ្លូវភេទលើកុមារ។[10] ភស្តុតាងដែលប្រមូលបានពីករណីដែលបានរកឃើញ និងរបាយការណ៍ដែលបានមកពីតំបន់នេះបង្ហាញថាជនល្មើសដែលធ្វើដំណើរទៅកន្លែងផ្សេងៗដើម្បីធ្វើការរំលោភបំពានផ្លូវភេទលើកុមារកំណត់យកគោលដៅកុមារដែលធ្វើការតាមចិញ្ចើមថ្នល់ ឬអាជីវកម្មមិនផ្លូវការផ្សេងៗនៅតាមគោលដៅទេសចរណ៍។[11] បន្ថែមពីនេះទៅទៀត ពួកគេក៏អាចទៅជួបកុមារដោយគ្មានការត្រួតពិនិត្យតាមរយៈការធ្វើការនៅតាមសាលារៀន ឬមណ្ឌលកុមារកំព្រា។ បើគ្មានការត្រួតពិនិត្យ និងឃ្លាំមើលសុវត្ថិភាពឲ្យបានហ្មត់ចត់ទេ ឧស្សាហ៍កម្មទេសចរណ៍ជួនកាលសម្រួលឲ្យជនល្មើសបានទៅជួបកុមារា និងកុមារី ងាយរងគ្រោះ ហើយបើមិនយកចិត្តទុកដាក់ទេ វានឹងនាំឲ្យមានការកេងប្រវ័ញ្ចលើកុមារ។ ប្រការនេះមិនមែនកើតឡើងតែក្នុងអាជីវកម្មទេសចរណ៍ខ្នាតធំ (ដូចជា សណ្ឋាគារ ភោជនីយដ្ឋាន រង្គសាល ផ្សារ និងបរិវេណតំបន់កំសាន្តរបស់ ភ្ញៀវទេសចរ)នោះទេ ប៉ុន្តែវាក៏កើតឡើងតាមសហគ្រាសដែលស្គាល់ថាជា "ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ" ឬ "ទេសចរណ៍វប្បធម៌"។ ឧទាហរណ៍ "ទេសចរណ៍ទៅ

9 សម្រាប់ព័ត៌មានបន្ថែម សូមមើលក្រុមប្រឹក្សាទេសចរណ៍និងធ្វើដំណើរ ពិភពលោក (២០១២) ឥទ្ធិពលសេដ្ឋកិច្ចនៃវិស័យទេសចរណ៍ និងធ្វើដំណើរ៖ កម្ពុជា ក្រុមប្រឹក្សាធ្វើដំណើរ និងទេសចរណ៍ពិភពលោក (២០១២) ឥទ្ធិពលសេដ្ឋកិច្ចនៃវិស័យទេសចរណ៍ និងធ្វើដំណើរ៖ ឡាវ ក្រុមប្រឹក្សាទេសចរណ៍និងធ្វើដំណើរពិភពលោក (២០១២) ឥទ្ធិពលសេដ្ឋកិច្ចនៃវិស័យធ្វើដំណើរ និងទេសចរណ៍៖ ថៃ និងក្រុមប្រឹក្សាធ្វើដំណើរ និងទេសចរណ៍ពិភពលោក (២០១២) ឥទ្ធិពលសេដ្ឋកិច្ចនៃវិស័យទេសចរណ៍និងធ្វើដំណើរ៖ វៀតណាម លើគេហទំព័រ www.wttc.org/research/ ចូលមើលនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២

10 ជនល្មើសដែលធ្វើដំណើរទៅកន្លែងផ្សេងៗដើម្បីធ្វើការរំលោភបំពានផ្លូវភេទលើកុមារ គឺជាជនទាំងឡាយណាដែលធ្វើដំណើរចេញពីប្រទេសរបស់ខ្លួន និងរំលោភបំពានផ្លូវភេទលើកុមារ។

11 គម្រោងកុមារភាព ផ្ទែកបង្ការ (២០១១)។ ការសិក្សាពីឯកសារមានស្រាប់។មិនបានបោះពុម្ពផ្សាយ។

កាន់មណ្ឌលកុមារកំព្រា" ដែលភ្ញៀវទេសចរត្រូវបានអនុញ្ញាតឲ្យចូលទៅទស្សនា និងមានអន្តរសកម្មភាពជាមួយកុមារដែលទទួលការថែទាំនៅមណ្ឌល[12] អាចធ្វើឲ្យកុមារងាយរងគ្រោះដោយការកេងប្រវ័ញ្ច។ រឿងនេះក៏កើតឡើងផងដែរចំពោះទម្រង់ផ្សេងៗនៃ "ទេសចរណ៍ធ្វើការស្ម័គ្រចិត្ត"[13] បើសិនគ្មានការត្រួតពិនិត្យឲ្យបានហ្មត់ចត់ចំពោះមនុស្សពេញវ័យដែលធ្វើការជាមួយកុមារ និង "ការស្នាក់នៅតាមផ្ទះ" ដែលមនុស្សពេញវ័យ មិនធ្លាប់ស្គាល់ស្នាក់នៅតាមផ្ទះរបស់ប្រជាជនក្នុងស្រុក មានទំនាក់ទំនងដោយគ្មានការត្រួតពិនិត្យជាមួយកុមារក្នុងស្រុក។

ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីការពារកុមារទល់នឹងការរំលោភបំពានផ្លូវភេទក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិបានចាប់ផ្តើមគម្រោងកុមារភាព ក្រោមគំនិតផ្តួចផ្តើមបង្ការ និងការពាររួមគ្នា ដែលអនុវត្តដោយអង្គការទស្សនៈពិភពលោក ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម និងអ៊ីនធឺប៉ូល ( INTERPOL )។ ដើម្បីរួមចំណែកដល់កិច្ចការនេះ អង្គការទស្សនៈពិភពលោកកំពុងធ្វើការជាមួយសហគមន៍ និងរដ្ឋាភិបាលដើម្បីទប់ស្កាត់កុំឲ្យកុមារី និងកុមារាក្លាយជាជនរងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍ និងបង្កើតនូវការអនុវត្ត និងគំនិតផ្តួចផ្តើមនៃ "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍"។ ដើម្បីសម្រេចតាមគោលដៅនេះ បច្ចុប្បន្ន អង្គការទស្សនៈពិភពលោកកំពុងចែកចាយការស្ទាបស្ទង់មតិតាមប្រព័ន្ធអ៊ីនធឺណេតជូនដល់អ្នកដំណើរអន្តរជាតិ ដើម្បីស្វែងយល់ ពីការយល់ឃើញ និងការយល់ដឹងរបស់ពួកគេចំពោះសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ក៏ដូចជាការជួបប្រទះ និងបទពិសោធន៍របស់ពួកគេជាមួយកុមារក្នុងប្រទេសទាំងនេះ។

អង្គការទស្សនៈពិភពលោក កំណត់និយមន័យនៃសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ថាជាទម្រង់ទេសចរណ៍ដែល ៖

១. ទទួលស្គាល់នូវតួនាទី និងឥទ្ធិពលរបស់ខ្លួនដែលអាចមានទៅលើការកេងប្រវ័ញ្ចលើមកុមារ
២. ទទួលខុសត្រូវក្នុងការកាត់បន្ថយនូវឥទ្ធិពលគ្រោះថ្នាក់ ( ដោយផ្ទាល់ និងដោយប្រយោល ) ទៅលើកុមារងាយរងគ្រោះ
៣. ដើរតួនាទីសកម្មក្នុងការពង្រឹង និងរក្សាបរិយាកាសមានសុវត្ថិភាពសម្រាប់កុមារគ្រប់រូប។ បើអាចទៅរួចសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ត្រូវបានគេមើលឃើញថាជាការផ្តល់ជូននូវដំណោះស្រាយប្រកបដោយនិរន្តរភាពរយៈពេលវែងក្នុងការរក្សាសុវត្ថិភាពកុមារពីការរំលោភបំពានក្នុងវិស័យ ទេសចរណ៍។ ហេតុនេះ វាជាមធ្យោបាយដ៏សំខាន់ដែលគប្បីអភិវឌ្ឍក្នុងឧស្សាហកម្មទេសចរណ៍កាន់តែមាន និរន្តរភាព និងវិជ្ជមាន ។

---

12 ប្រការនេះអាចរាប់ចាប់ពីការផ្តល់ឱកាសឲ្យមនុស្សបង្រៀនភាសាអង់គ្លេស ឬថែទាំកុមារក្នុងមណ្ឌលកុមារកំព្រា រហូតដល់ផ្តល់ឱកាសឲ្យភ្ញៀវទេសចរធ្វើដំណើរកំសាន្តពេលថ្ងៃមកកាន់មណ្ឌលកុមារកំព្រា ឬមណ្ឌលថែរក្សាកុមារ។ ក្នុងករណីភាគច្រើន ភ្ញៀវទេសចរបង់ប្រាក់ដើម្បីចូលទៅមើលកុមារទាំងនេះ។

13 ទេសចរណ៍ធ្វើការស្ម័គ្រចិត្តជាធម្មតាត្រូវបានគេស្គាល់ថាជាទម្រង់មួយនៃវិស័យទេសចរណ៍ដែលអ្នកដំណើរទទួលបានឱកាសធ្វើការងារស្ម័គ្រចិត្តជាមួយអង្គការ ឬសហគ្រាសជាក់លាក់នៅតាមប្រទេសដែលជាកន្លែងគោលដៅទេសចរណ៍។ ការងារនេះអាចមានរយៈពេលជាច្រើនថ្ងៃ ច្រើនសប្តាហ៍ ឬច្រើនខែ ហើយក៏ដូចជាវិស័យទេសចរណ៍នៅតាមមណ្ឌលកុមារកំព្រាដែរ អ្នកដែលជ្រើសរើសទម្រង់ទេសចរណ៍បែបនេះជារឿយៗត្រូវបង់ប្រាក់ ដើម្បីចូលរួម ( ជួនកាលការបង់អាចធ្វើឡើងជាមូលនិធិដើម្បីគ្របដណ្តប់លើ អាហារ និងកន្លែងស្នាក់នៅ ក្នុងករណីខ្លះទៀតមានថ្លៃឈ្នួលដើម្បីអាចចូលរួម )។ នៅអាស៊ីអាគ្នេយ៍ គម្រោងការងារស្ម័គ្រចិត្តរួមមាន៖ ការបង្រៀនភាសាអង់គ្លេសដល់កុមារ មនុស្សវ័យជំទង់ និង/ឬមនុស្សពេញវ័យ ការធ្វើការក្នុងគម្រោងអភិវឌ្ឍសហគមន៍ ការធ្វើការ ក្នុងការថែទាំសុខភាព និងការធ្វើការក្នុងការអភិរក្សបរិស្ថាន និង/ឬសត្វព្រៃ។ អ្នកធ្វើការស្ម័គ្រចិត្តជារឿយៗស្នាក់នៅតាមសហគមន៍ក្នុងស្រុក ( និងជួនកាលតាមផ្ទះបុគ្គលិកគម្រោង ) និងត្រូវបានលើកទឹកចិត្តឲ្យផ្លាស់ប្តូរវប្បធម៌ជាផ្នែកនៃបទពិសោធន៍ធ្វើការងារស្ម័គ្រចិត្ត។

ដើម្បីជួយដល់គម្រោងកុមារភាព និងភ្នាក់ងារដទៃទៀតក្នុងការគាំទ្រដល់ការអភិវឌ្ឍបរិយាកាស ការពារសម្រាប់កុមារក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍ ការស្ទាបស្ទង់មតិនេះ ដែលរួមមានសំណួរបើក និងសំណួរបិទត្រូវបានចាប់អនុវត្តពីខែឧសភា ដល់ខែមិថុនា ឆ្នាំ២០១២។ របាយការណ៍នេះផ្តល់នូវសេចក្តីសង្ខេបនៃការស្រាវជ្រាវនេះ និងពិភាក្សាពីលទ្ធផលនៃការវិភាគទិន្ន័យបែបបរិមាណ និងបែបគុណភាព។

# ឧបសគ្គ និងភាពមានកម្រិតនៃទិន្នន័យ

សំណាកគំរូនៃការស្ទាបស្ទង់មតិនេះមានភាពលម្អៀងលើអាយុ ភេទ សញ្ជាតិ និងអាចកាន់តែសំខាន់ទៅទៀតគឺប្រភេទនៃអ្នកដំណើរ។ ប្រការនេះគឺបណ្តាលមកពីវាជាការស្ទាបស្ទង់មតិតាមអ៊ីនធឺណេតជាភាសាអង់គ្លេស និងចែកចាយតាមអ៊ីនធឺណេតលើគេហទំព័រដែលអ្នកដំណើរឯករាជ្យនិយមចូលមើល។ ការជ្រើសរើសអ្នកចូលរួមតាមក្រុមហ៊ុន Intrepid Travel ក៏មានន័យថាអ្នកឆ្លើយតបភាគច្រើនបានយល់ដឹងពីការធ្វើដំណើរប្រកបដោយការទទួលខុសត្រូវ ( ជាការពិត នេះគឺជាមោទនភាពរបស់ក្រុមហ៊ុន Intrepid )។[14] លើសពីនេះ រយៈពេលប្រមូលទិន្នន័យមួយខែធ្វើឲ្យយើងទទួលបានទំហំសំណាកគំរូត្រឹម៣១៦នាក់ដែលជាទំហំរាងតូចបន្តិច បើទោះជាវាមិនប៉ះពាល់ខ្លាំងដល់លទ្ធផលក៏ដោយ។ ជាលទ្ធផល លទ្ធភាព ក្នុងការទាញសេចក្តីសន្និដ្ឋានស្ថិតិពីសំណាកគំរូនៃការស្ទាបស្ទង់មតិនេះដើម្បីតំណាងឲ្យប្រជាជនដែលត្រូវសិក្សាគឺនៅមានកម្រិត។ ទោះបីជាយ៉ាងនេះក្តី ក៏លទ្ធផលនៃការស្ទាបស្ទង់មតិនេះផ្តល់នូវចំណុចចាប់ផ្តើមដ៏ល្អសម្រាប់អភិវឌ្ឍយុទ្ធសាស្ត្រទាក់ទងនឹងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។

# អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិស្តីពី សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

ការស្រាវជ្រាវនេះប្រព្រឹត្តទៅក្នុងរយៈពេលមួយខែ ត្រូវបានចែកចាយតាមអ៊ីនធឺណេតជាភាសាអង់គ្លេសតាមរយៈគេហទំព័រ SurveyMonkey។ វាត្រូវបានផ្សព្វផ្សាយដល់អ្នកដែលអាចចូលរួម តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ( ដូចជា Twitter និង Facebook ) បណ្តាញអ៊ីមែល វេទិការតាមអ៊ីនធឺណេត ( ដូចជា Yammer ) និងតាមគេហទំព័រ និងប្លុកស្តីពីទេសចរណ៍។ ឧទាហរណ៍ អ្នកចូលរួមម្នាក់បង្ហាញថាគាត់បានដឹងពីការស្ទាបស្ទង់មតិនេះពីភ្នាក់ងារធ្វើដំណើរយុវជន STA Travel ហើយអ្នកចូលរួមមួយចំនួនចូលទៅមើលការស្ទាបស្ទង់មតិនេះបន្ទាប់ពីវាត្រូវបានផ្សព្វផ្សាយដោយក្រុមហ៊ុនទេសចរណ៍សម្រាប់ដំណើរកំសាន្តជាក្រុមតូចនៃប្រទេសអូស្ត្រាលីឈ្មោះថា Intrepid Travel។

មធ្យោបាយសំខាន់ដែលអ្នកចូលរួមភាគច្រើន( ៣៨% ) ត្រូវបានជ្រើសរើសឲ្យចូលរួមក្នុងការស្ទាបស្ទង់មតិនេះគឺតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។
មធ្យោបាយដ៏សំខាន់ស្រដៀងគ្នាបន្ទាប់មកទៀតគឺកាសែត Intrepid Express (ដែលជាការបោះពុម្ពផ្សាយផ្អែកតាមការចុះឈ្មោះសម្រាប់ចែកជូនអ្នកចូលរួមក្នុងដំណើរកំសាន្តតាមក្រុមហ៊ុន Intrepid ពីមុន

14 បើទោះជាការធ្វើទេសចរណ៍តាម Intrepid ត្រូវបានផ្សព្វផ្សាយ និងធ្វើឡើងទូទាំងពិភពលោក ក៏ក្រុមហ៊ុននេះមានមូលដ្ឋាននៅប្រទេសអូស្ត្រាលី ហើយប្រការនេះអាចរួមចំណែកនាំឲ្យមានអ្នកចូលរួមជាជនជាតិអូស្ត្រាលីជាច្រើននៅក្នុងការស្ទាបស្ទង់មតិនេះ ( ដូចមានរៀបចំជាឯកសារនៅក្នុងរូបភាពទី៣ )។ សម្រាប់ព័ត៌មានបន្ថែមអំពីក្រុមហ៊ុន Intrepid និងប្រតិបត្តិការរបស់ក្រុមហ៊ុននេះ សូមចូលទៅគេហទំព័រ www. intrepidtravel.com។

ឬបំរុងនឹងចូលរួម) (៣១%) និងបណ្ដាញអ៊ីមែលជាលក្ខណៈបុគ្គល(២៥,៦%)។ លទ្ធផលទទួលបានគឺទំហំសំណាកគំរូជ្រើសរើសខ្លួនឯងនៃអ្នកចូលរួមចំនួន៥៣៣នាក់។ ក្នុងចំណោមអ្នកចូលរួមទាំង៥៣៣នាក់នេះ ត្រឹមតែ៤៤២នាក់ប៉ុណ្ណោះដែលបានធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាមក្នុងរវាង៥ឆ្នាំចុងក្រោយ សល់ពីនេះត្រូវបានដកចេញដោយសារកង្វះចំណេះដឹងផ្ទាល់ខ្លួនបច្ចុប្បន្ន និង/ឬ បទពិសោធន៍នៃការធ្វើដំណើរទៅកាន់តំបន់នេះ។ ដោយសារអ្នកចូលរួមខ្លះមិនបានឆ្លើយអស់តាមសំណួរក្នុងការស្ទាបស្ទង់មតិនេះ ហេតុនេះចំនួនចុងក្រោយនៃអ្នកចូលរួមគឺ ៣១៦នាក់។

# តើអ្នកចូលរួមទាំងនេះធ្វើដំណើរទៅណា និងដើម្បីអ្វី ?

ទិន្នន័យប្រជាសាស្ត្រដែលប្រមូលបានតាមរយៈការស្ទាបស្ទង់មតិនេះ បង្ហាញថាភាគច្រើនលើសលុប (៧១,៤%) នៃអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះគឺជាស្ត្រី អាយុពី៣០-៣៩ឆ្នាំ ហើយចំណាយ ពេលជាមធ្យមពី ១-៤ សប្តាហ៍នៅក្នុងប្រទេសយ៉ាងតិចមួយក្នុងចំណោមប្រទេសគោលដៅទេសចរណ៍នេះក្នុងរវាង ៥ឆ្នាំចុងក្រោយ។ ប្រទេសដែលនិយមទៅទស្សនាជាងគេគឺប្រទេសថៃ បន្ទាប់មកគឺប្រទេសកម្ពុជា វៀតណាម និងប្រទេសឡាវ (សូមមើលរូបភាពទី១)។ អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិភាគច្រើនបង្ហាញថាពួកគេបានធ្វើ ដំណើរទៅតំបន់នេះសម្រាប់វិស្សមកាល(៥៩,៧%) ក៏ប៉ុន្តែ អ្នកចូលរួមចំនួនទៅទស្សនាតំបន់នេះក្នុងគោលបំណងអាជីវកម្ម និងការងារ(២៦,៨%)។ អ្នកចូលរួមខ្លះទៀតបង្ហាញថាគោលបំណងចម្បងនៃការធ្វើដំណើរបស់ពួកគេគឺដើម្បីទៅលេងគ្រួសារ ឬមិត្តភក្តិ(៥%) ដើម្បីសិក្សា ឬចុះកម្មសិក្សា(0,៨%) ហេតុផលសាសនា (0,៥%) ឬធ្វើការស្ម័គ្រចិត្ត (២,៩%)។ ស្របតាមនិន្នាការទេសចរណ៍បច្ចុប្បន្ន (ភាពចម្រុះនៃមូលហេតុ និងប្រភេទនៃការធ្វើដំណើររបស់ភ្ញៀវទេសចរ) អ្នកចូលរួមមួយចំនួន(៤,៧%) បង្ហាញថាការធ្វើដំណើររបស់ពួកគេមានគោលដៅពីរព្រមគ្នា (ឧទាហរណ៍ ដំណើរកំសាន្តផងនិងធ្វើការស្ម័គ្រចិត្តផង ឬដើម្បីធ្វើអាជីវកម្មផងនិងកំសាន្តវិស្សមកាលផង)។

គួរឲ្យចាប់អារម្មណ៍ បើទោះជាអ្នកចូលរួម ២៩,២% បាន ទស្សនាប្រទេសតែមួយក្នុងតំបន់នេះ ក៏ប៉ុន្តែ ២១,៣% នៃអ្នកចូលរួមបានទស្សនាប្រទេសទាំងបួនក្នុងរវាង៥ឆ្នាំចុងក្រោយ ២៨,២% បានទស្សនាប្រទេសបីក្នុងចំណោមប្រទេសទាំងបួន ២១,៣%បានទស្សនាប្រទេសពីរ ហើយ ចម្លើយបែបគុណភាពបង្ហាញថាអ្នកចូលរួមមួយចំនួនក្នុងការស្ទាបស្ទង់មតិនេះបានទៅទស្សនាតំបន់នេះសាជាថ្មី (មិនថាពួកគេធ្លាប់បានទស្សនាប្រទេសមួយ ពីរ បី ឬបួន)។ ការធ្វើដំណើរទៅកំសាន្តនៅប្រទេសច្រើន ឬសាជាថ្មីនេះអាចត្រូវបានបកស្រាយមួយចំណែកដោសារ ភាគច្រើននៃអ្នកចូលរួមគឺមានទីលំនៅនៅប្រទេសអាស៊ីប៉ាស៊ីហ្វិក។ ឧទាហរណ៍អ្នកស្នាក់នៅប្រទេស អូស្ត្រាលី និងញូវហ្ស៊ីលែន (ដែលការធ្វើដំណើរទៅប្រទេសអាស៊ីអាគ្នេយ៍គឺនៅជិត ហើយចំណាយតិច) មានចំនួនច្រើនលើសលប់[15] ចំណុចនេះក៏មានដូចគ្នាចំពោះបុគ្គលដែលស្នាក់នៅក្នុង ប្រទេសកម្ពុជា និងប្រទេសថៃ ដែលភាគច្រើនបើគេប្រៀបធៀបប្រទេសស្នាក់នៅ និងប្រទេសនៃការស្ទាបស្ទង់មតិនេះដែលបានបំពេញ គឺជាជនដែលធ្វើការនៅបរទេស។[16]

---

15 ប្រកានេះ រួមនឹងអត្រាខ្ពស់នៃអ្នកចូលរួមជាជនជាតិអាមេរិក និងអង់គ្លេសក៏អាចពន្យល់បានដោយសារការស្ទាបស្ទង់មតិនេះធ្វើឡើងជាភាសាអង់គ្លេស។

16 ការបកប្រែលទ្ធផលនេះត្រូវបានពង្រឹងបន្ថែមដោយចំណុចដែល៩,៧% នៃអ្នកចូលរួមបានចំណាយពេលយូរជាង៦ខែក្នុងប្រទេសកម្ពុជា និង៤,២%នៃអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះបានចំណាយពេលលើសពី៦ខែក្នុងប្រទេសថៃ។

រូបភាពទី១ ៖ សមាមាត្រនៃអ្នកចូលរួមដែលទស្សនាប្រទេសនីមួយៗ




ក្រៅពីនេះ ដោយសារអត្រានៃអ្នកស្នាក់នៅអាមេរិក និងអង់គ្លេសដែលចូលរួមក្នុងការស្ទាបស្ទង់មតិនេះ (ភាគច្រើនមិនមែនជាអ្នកធ្វើការនៅបរទេស ឬស្នាក់នៅជិតតំបន់នេះ) នោះឆ្លុះបញ្ចាំងថាតំបន់នេះពិតជាមានប្រជាប្រិយភាពចំពោះអ្នកដំណើរទូទាំងពិភពលោក ពិសេសអ្នកដំណើរវ័យក្មេង ដែលជាអ្នកចូលរួមភាគច្រើននៃសំណាកគំរូនេះ (៦៦,៥៦% មានអាយុពី២០-៣៩ឆ្នាំ)។ សម្រាប់ការបែងចែកអាយុបន្តទៀតរបស់អ្នកចូលរួមសូមមើលរូបភាពទី២ និងរូបភាពទី៣។

រូបភាពទី២ ៖ ការបែងចែកអ្នកចូលរួមតាមអាយុ



រូបភាពទី៣ ៖ ប្រទេសដែលអ្នកចូលរួមស្នាក់នៅ




# ប្រភេទ និងបែបបទនៃការធ្វើដំណើរ

បើនិយាយពីប្រភេទនៃការធ្វើដំណើររបស់អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះ ក្នុងពេលស្នាក់នៅក្នុងតំបន់នេះ គឺមាន ៥៨,៧%ចាត់ទុកខ្លួនថាបាន "ធ្វើដំណើរឯករាជ្យ" ១៣,៤%និយាយថាពួកគេភាគច្រើនបានធ្វើដំណើរជា "អ្នកដំណើរសាក់កាដូ" ២១,៨%បង្ហាញថាពួកគេបានចូលរួមជាមួយដំណើរកំសាន្តរៀបចំដោយក្រុមហ៊ុន (ភាគច្រើនគឺជាមួយក្រុមហ៊ុន Intrepid) និង ១៧,៣% បង្ហាញថាពួកគេបានធ្វើដំណើរតាមប្រភេទ និងបែបបទជាច្រើនខុសៗគ្នានៅពេលស្នាក់នៅក្នុងតំបន់នេះ (ជួនកាលឆ្លងកាត់ការធ្វើដំណើរ

ខុសៗគ្នា )។[17] បន្ថែមពីនេះទៅទៀត អ្នកចូលរួម១៧,៦%និយាយថាពួកគេភាគច្រើនបានធ្វើដំណើរជាមួយដៃគូ និង/ឬគ្រួសារពួកគេ ៥,៨%បានធ្វើដំណើរជាមួយមិត្តភក្តិ និង៩,២% បានធ្វើដំណើរជាមួយអ្នករួមការងារ។ ជាថ្មីម្តងទៀត ដោយសារមានអ្នកដំណើរជាមនុស្សវ័យក្មេងច្រើននៅក្នុងការស្ទាបស្ទង់មតិនេះ[18] នោះគ្មានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលទេ ដែលគេឃើញមានអ្នកដំណើរឯករាជ្យ ឬអ្នកដំណើរសាក់កាដូជាច្រើន ដែលជាប្រភេទនៃការធ្វើដំណើរដែលពេញនិយមសម្រាប់ភ្ញៀវទេសចរអាយុវ័យក្មេង។ និន្នាការដូចគ្នានេះ ( ចំពោះអ្នកដំណើរវ័យក្មេង និងអ្នកដំណើរឯករាជ្យ ) ក៏អាចជួយពន្យល់ពីប្រេវ៉ាឡង់ដ៏ខ្ពស់នៃប្រព័ន្ធផ្សព្វផ្សាយ តាមអ៊ីនធឺណេត និងសៀវភៅមគ្គុទ្ទេសក៍នៅក្នុងការរៀបផែនការធ្វើដំណើរ។

# ការរៀបផែនការធ្វើដំណើរ និងការចូលរួមជាមួយប្រព័ន្ធផ្សព្វផ្សាយផ្នែកធ្វើដំណើរ

នៅពេលសួរថាតើពួកគេប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអ្វី ដើម្បីរៀបផែនការធ្វើដំណើររបស់ពួកគេមកកាន់តំបន់នេះ ភាគច្រើនលើសលុប( ៧២,៤% ) នៃអ្នកឆ្លើយតបចំពោះការស្ទាបស្ទង់មតិនេះបង្ហាញថាពួកគេបានប្រើប្រាស់គេហទំព័រ និង "កម្មវិធី" ( apps )[19]  ទេសចរណ៍។ បន្ទាប់ពីប្រព័ន្ធផ្សព្វផ្សាយតាមអ៊ីនធឺណេត គឺសៀវភៅមគ្គុទ្ទេសក៍ ដែលត្រូវបានប្រើដោយ៦៦,៦%នៃភ្ញៀវទេសចរដែលត្រូវបានស្ទាបស្ទង់មតិ។ ប្រភពផ្សេងទៀតនៃព័ត៌មានដែលសំខាន់ដែរនោះ ( ទោះជាមិនសូវត្រូវបានលើកឡើងញឹកញាប់ ) សម្រាប់អ្នកឆ្លើយតប ចំពោះការស្ទាបស្ទង់មតិនេះរួមមាន ភ្នាក់ងារទេសចរណ៍ អ្នកមគ្គុទ្ទេសក៍ទេសចរ និងអ្នករៀបរាប់ត្រួសៗ សម្រាប់ភ្ញៀវទេសចរ ក្រុមហ៊ុនអាកាសចរណ៍ គេហទំព័រកក់កន្លែងស្នាក់នៅដូចជា ( Agoda, Expedia និង Hostel World ) និងការណែនាំផ្ទាល់មាត់ពីមិត្តភក្តិ និងគ្រួសារ។ គេហទំព័របង្កើតដោយអ្នកប្រើប្រាស់ ( ដូចជា Trip Advisor និង Travelfish ) ក៏ត្រូវបានលើកឡើងញឹកញាប់ផងដែរ។

ប្រការខាងលើនេះបង្ហាញថា ទោះជាមានក្រុមសំណាកគំរូជាក់លាក់របស់ការស្ទាបស្ទង់មតិនេះ ( ដូចជាអ្នកដំណើរភាគច្រើនជាស្ត្រី មនុស្សវ័យក្មេង ជនជាតិអូស្ត្រាលី អ្នកដំណើរឯករាជ្យ/អ្នកដំណើរសាក់កាដូ និងអ្នកធ្វើការនៅបរទេស/តាមអង្គការមិនមែនរដ្ឋាភិបាល ) ក៏គេនៅតែឃើញភាព

17 ភាគច្រើននៃបច្ចេកវិទ្យាដែលប្រើដោយអ្នកដំណើរដើម្បីពណ៌នាពីប្រភេទនៃការធ្វើដំណើរជារឿយមានលក្ខណៈមិនច្បាស់ ហើយការពណ៌នាបែបនេះជារឿយៗមានអត្ថន័យផ្សេងៗគ្នាទៅតាមអ្នកចូលរួមម្នាក់ៗ។ តាមពិតទៅ មានភស្តុតាងនៃអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះប្រើពាក្យថាការធ្វើដំណើរឯករាជ្យមានន័យថាជាការធ្វើដំណើរដែលមិនស្ថិតក្រោមការរៀបចំដោយស្ថាប័នមួយ ឬការធ្វើដំណើរដែលមិនសូវអាស្រ័យលើឧស្សាហកម្មទេសចរណ៍ ( ន័យធម្មតា ) ហើយក៏មានន័យថាការធ្វើដំណើរតែម្នាក់ឯងផងដែរ។ ក្នុងពេលបកប្រែលទ្ធផលនៃស្ថិតិទាំងនេះ គេគប្បីចង្អុលបង្ហាញថាពាក្យថា ការធ្វើដំណើរដោយស្ពាយសាក់កាដូ និងការធ្វើដំណើរដោយឯករាជ្យ ជារឿយៗត្រូវបានប្រើជំនួសគ្នាទៅវិញទៅមក ហើយក្នុងករណីខ្លះការប្រើពាក្យថា "ធ្វើដំណើរដោយស្ពាយសាក់កាដូ" បង្ហាញពីការផ្សារភ្ជាប់ខាងវប្បធម៌ និងលក្ខណៈនៃអត្តសញ្ញាណ ( ថាមនុស្សម្នាក់ជាអ្នកដំណើរដោយស្ពាយសាក់កាដូ/មានវប្បធម៌ធ្វើដំណើរដោយស្ពាយសាក់កាដូ ) ជាជាងទម្លាប់/ការអនុវត្តធ្វើដំណើរជាក់លាក់មួយ។ ទោះជាយ៉ាងនេះក្តី ក៏មានភាពខុសគ្នាយ៉ាងច្បាស់នៅក្នុងសំណាកគំរូនេះរវាងអ្នកដែលធ្វើដំណើរតាមការរៀបចំដោយក្រុមហ៊ុន និងអ្នកដែលមិនធ្វើដំណើរតាមការរៀបចំដោយក្រុមហ៊ុន។

18 ដូចដែលបានបង្ហាញរួចហើយ ចំណុចនេះអាចបណ្តាលមកពីប្រជាប្រិយភាពនៃអាស៊ីអាគ្នេយ៍ ( ដែលជារឿយៗត្រូវបានអ្នកដំណើរវ័យក្មេងយល់ថាជាកន្លែងគោលដៅទេសចរណ៍ដែលកាន់តែ "ផ្សងព្រេង"។ ម្យ៉ាងវិញទៀតប្រការនេះក៏អាចទទួលឥទ្ធិពលដោយសារការស្ទាបស្ទង់មតិនេះត្រូវបានផ្សព្វផ្សាយខ្លាំងតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងធ្វើឡើងតាមអ៊ីនធឺណេត ដែលជាបរិយាកាសសម្រាប់មនុស្សមានអាយុ ឬចន្លោះជំនាន់ច្បាស់លាស់។

19 កម្មវិធី Software ដែលជាធម្មតាប្រើដោយទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិចយកតាមខ្លួនបាន។

ចម្រុះគ្នានៃមូលហេតុ បែបបទ/ប្រភេទនៃការធ្វើដំណើរ សញ្ជាតិ និងក្រុមអាយុដែលតំណាងឲ្យទិន្នន័យដំបូងនេះ។ ចំណុចនេះមានសារៈសំខាន់ បើគេពិចារណាថាគ្រប់បែបបទធ្វើដំណើរ ឬគោលបំណង អាយុ ឬភេទ គឺអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះសុទ្ធតែរាយការណ៍ថាមានអន្តរសកម្មភាពជាមួយសហគមន៍ក្នុងស្រុកក្នុងប្រទេសដែលពួកគេទស្សនា និងជាពិសេសគឺមានអន្តរសកម្មភាពជាមួយកុមារ។

# ការសង្កេតលើកុមារ និងការប្រាស្រ័យទាក់ទងនឹងកុមារនៅក្នុងតំបន់

ក្នុងចំណោមអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិទាំង ៣១៦នាក់ ដែលឆ្លើយនឹងសំណួរស្តីពីការសង្កេតរបស់ពួកគេលើកុមារ និងអន្តរសកម្មភាពជាមួយកុមារ និងមនុស្សវ័យក្មេងក្នុងតំបន់នេះ ភាគច្រើនបង្ហាញថាពួកគេបានប្រាស្រ័យទាក់ទងជាមួយកុមារ។ ភាគច្រើន ប្រការនេះមានទម្រង់ជាការឃើញ ឬត្រូវបានមនុស្សវ័យក្មេងព្យាយាមលក់វត្ថុអនុស្សាវរីយ៍ឲ្យពួកគេ(៨៥%) ឬសុំទានពីពួកគេ(៨១,២%) (សូមមើលរូបភាពទី៤)។ អ្នកចូលរួមភាគច្រើនក៏រាយការណ៍ថាបានឃើញកុមារដើររើសសំរាម(៥៩%) ធ្វើការតាមភោជនីយដ្ឋាន និងសណ្ឋាគារ(៤៨,៥%) និងសម្តែងសិល្បៈតាមចិញ្ចើមថ្នល់(៣៨%)។ អ្នកចូលរួមមួយចំនួនក៏បានអះអាងថាពួកគេបានឃើញកុមារ ឬមនុស្សវ័យក្មេង(អាយុក្រោម ១៨ឆ្នាំ) ធ្វើការជាអ្នកមគ្គុទ្ទេសក៍ទេសចរ(២៥,៥%) និងកាន់តែគួរឲ្យបារម្ភបំផុត គឺធ្វើការក្នុងរបររកស៊ីផ្លូវភេទ(២០,៥%)។

អន្តរសកម្មភាពផ្សេងទៀតដែលត្រូវបានរាយការណ៍ជារឿយៗរួមមានការជជែក ឬលេងកំសាន្តជាមួយកុមារ។ ត្រង់ចំណុចនេះ គេឧស្សាហ៍ឃើញការលើកឡើងដូចខាងក្រោម ៖

> ជារឿយៗ ពួកគេ(កុមារ) មករកខ្ញុំ និងចង់អនុវត្តការនិយាយភាសាអង់គ្លេស ហើយខ្ញុំក៏តែងតែរីករាយក្នុងការនិយាយជាមួយពួកគេអំពីជីវិតរបស់ពួកគេ។ (ស្ត្រី ជនជាតិអូស្ត្រាលី អាយុ៣៥ឆ្នាំ)
>
> យើងនិយាយជាមួយកុមារជនបទ ពីព្រោះពួកគេមករកពួកយើងប្រកបដោយការរំភើបចិត្តដោយបានជួប និងស្វាគមន៍ពួកយើង។ (ស្ត្រី ជនជាតិក្រូអាត អាយុ៣០ឆ្នាំ)
>
> មានក្មេងស្រីម្នាក់មករកខ្ញុំនៅពេលខ្ញុំកំពុងអានសៀវភៅក្នុងសួនឧទ្យាន។ នាងនិយាយភាសាអង់គ្លេសបានយ៉ាងល្អបើតាមអាយុរបស់នាង ហើយខ្ញុំ និងនាងបានឲ្យចំណីត្រីក្នុងអាងត្រីជាមួយគ្នា។ (ស្ត្រី ជនជាតិអង់គ្លេស អាយុ៣៧ឆ្នាំ)
>
> កុមារនឹងរត់មកក្រៅផ្ទះ ហើយស្វាគមន៍ និងគ្រវីដៃដាក់អ្នក... (បុរស ជនជាតិកូស្តារីកា អាយុ៤៣ឆ្នាំ)

ជារឿយៗ មានការសង្កត់ធ្ងន់ថាភ្ញៀវទេសចរនិយាយ/លេងកំសាន្តជាមួយកុមារ ពីព្រោះកុមារមករកពួកគេ(មិនមែនដោយសារមូលហេតុផ្សេងនោះទេ)។ ស្រដៀងគ្នានេះដែរ អ្នកដែលរាយការណ៍ថាបានថតរូបកុមារមានទំនោរបង្ហាញថាគេធ្វើបែបនេះដោយសារកុមារសុំឲ្យថត (អាចនិយាយប្រាប់ដោយផ្ទាល់ ឬដោយប្រយោល) ឬយ៉ាងហោចណាស់ ដើម្បីឲ្យកុមារសប្បាយចិត្ត។

ឧទាហរណ៍ អ្នកចូលរួមរាយការណ៍ថា "(កុមារ) សប្បាយចិត្ត និងសុំឲ្យយើងថតរូបឲ្យពួកគេ នៅពេលយើងដើរលេងថតទេសភាពក្នុងភូមិ" និងថាពួកគេបានចំណាយពេល "និយាយជាមួយកុមារ និងថតរូបពួកគេដើម្បីបង្ហាញពួកគេនៅលើអេក្រង់"។ អ្នកចូលរួមម្នាក់ទៀតរាយការណ៍ថាបានជូនដំណើរ ប្រជាជនក្នុងស្រុកម្នាក់ ដោយកង់របស់គេ (នៅក្នុងភូមិមួយក្នុងប្រទេសឡាវ) ហើយត្រូវប្រជាជនក្នុងស្រុកអញ្ជើញឲ្យហូបអាហារជាមួយគ្រួសារប្រជាជនម្នាក់នោះ។ អ្នកចូលរួមម្នាក់នេះសង្កេតឃើញថា "កុមារចាប់អារម្មណ៍លើពួកយើង ហើយពួកគេថតរូបដោយប្រើម៉ាស៊ីនថតរបស់ខ្ញុំ" (ការសង្កត់ធ្ងន់តាមប្រភពដើម)។

អ្នកចូលរួមផ្សេងទៀតក្នុងការស្ទាបស្ទង់មតិនេះ រាយការណ៍ថាបានប្រាស្រ័យទាក់ទងជាមួយកុមារនៅពេលទៅ ទស្សនាសាលារៀន នៅពេលបង្រៀនភាសាអង់គ្លេស ឬនៅពេលធ្វើការងារ ឬកិច្ចការស្ម័គ្រចិត្តក្នុងតំបន់នេះ។ មានការរាយការណ៍ផងដែរពីការជួបជាមួយកុមារនៅពេលទស្សនាមណ្ឌលកុមារកំព្រា ឬកម្មវិធីស្នាក់នៅតាមផ្ទះ និងដោយកម្រ គឺប្រាស្រ័យទាក់ទងនឹងកុមារជាកូននៃមិត្តភក្តិ និងសមាជិកគ្រួសារនៅក្នុងតំបន់នេះ។ ភាគច្រើននៃអ្នកចូលរួមទាំងនេះ រាយការណ៍ថា តាមរយៈសកម្មភាពភ្ញៀវទេសចរតាមសហគមន៍ ដែលអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនិយាយថាពួកគេបានចូលរួមនៅពេលទៅលេងប្រទេសមួយក្នុងចំណោមប្រទេសទាំងបួននេះ មានការរំពឹងទុកថាមានអន្តរសកម្មភាពជាមួយកុមារ (សូមមើលរូបភាពទី៥)។

រូបភាពទី៤ ៖ ចម្លើយចំពោះសំណួរ "តើអ្នកមានឃើញកុមារ ឬមនុស្សវ័យក្មេង (អាយុក្រោម១៨ឆ្នាំ) ធ្វើសកម្មភាពដូចតទៅនៅក្នុងតំបន់នេះដែរឬទេ ?"




ជាទូទៅ អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះមានភាពទៀងត្រង់ចំពោះការប្រាស្រ័យទាក់ទងរបស់ពួកគេជាមួយកុមារ ហើយភាគច្រើនហាក់ដូចជាចងចាំច្បាស់អំពីអន្តរសកម្មភាពដែលពួកគេអាចនិយាយប្រាប់អ្នកដទៃដោយបើកចំហ។ ឧទាហរណ៍ អ្នកចូលរួមម្នាក់បានសរសេរថាគាត់បានឲ្យ

កុមារនូវ "ស្គរគ្រាប់ ថតរូប និងបង្ហាញរូបថតលើអេក្រង់ម៉ាស៊ីនថតរបស់ខ្ញុំ"។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបានរៀបរាប់ខាងលើ សម្រាប់អ្នកចូលរួមមួយចំនួន បញ្ហាអាចមានភាពស្មុគស្មាញបន្តិច ហើយភាគច្រើនមានអារម្មណ៍ថាចាំបាច់ត្រូវសម្របតាមបរិបទ ពន្យល់ ឬបកស្រាយរកអំណះអំណាងចំពោះអន្តរសកម្មភាពរបស់ពួកគេជាមួយកុមារនៅក្នុងតំបន់នេះ ពិសេសនៅពេលនិយាយពីការនិយាយជាមួយ ឬថតរូបឲ្យកុមារ។

រូបភាពទី៨ ៖ សកម្មភាពភ្ញៀវទេសចរតាមសហគមន៍ដែលធ្វើឡើងដោយអ្នកចូលរួម
ក្នុងការស្ទាបស្ទង់មតិនៅក្នុងតំបន់នេះ




និន្នាការនេះ អាចបង្ហាញថាមានការយល់ដឹងក្នុងកម្រិតមួយស្ដីពីបញ្ហាជុំវិញអន្តរសកម្មភាពរវាងកុមារម្ចាស់ស្រុក និងភ្ញៀវទេសចរ ត្រូវបានកត់សម្គាល់កាន់តែច្បាស់ បើនិយាយពីការពិភាក្សារបស់អ្នកចូលរួមសអំពីពេលដែលពួកគេព្យាយាមជួយ ពួកគេបានឲ្យរបស់ខ្លះដល់កុមារ (ដូចជាអាហារ ឬសម្លៀកបំពាក់)។ ជារឿយៗ នៅពេលព្យាយាមរៀបរាប់ពីអន្តរសកម្មភាពបែបនេះ អ្នកចូលរួមបង្ហាញក្ដីមន្ទិលចំពោះអ្វីដែលពួកគេបានធ្វើ និងអ្វីដែលពិតជាសកម្មភាពត្រឹមត្រូវក្នុងស្ថានភាពបែបនោះ។ ឧទាហរណ៍ អ្នកចូលរួមជាស្ត្រីម្នាក់លើកឡើងថាមានពេលមួយនោះ នាងបាននាំកុមារម្នាក់ទៅភោជនីយដ្ឋានដើម្បីហូបអាហារថ្ងៃត្រង់ នាងបានពន្យល់ថា ៖

> ក្មេងប្រុសម្នាក់នោះជាអ្នកលក់អ៊ីវ៉ាន់តាមចិញ្ចើមថ្នល់ ហើយខ្ញុំបដិសេធមិនទិញអ៊ីវ៉ាន់របស់គេ ហើយចុងក្រោយ គេប្រាប់ខ្ញុំថា "វាមិនស្រួលដូចអ្នកថានោះទេ"

ហើយដើរចេញដោយយំផង។ ខ្ញុំអាណិតក្មេងនោះណាស់។ ក្រោយមកខ្ញុំបានជួបគេទៀត ហើយខ្ញុំក៏សុំជួបម្តាយរបស់គេ ប៉ុន្តែចុងក្រោយរឿងនេះមិនអាចទៅរួច ហេតុនេះ ខ្ញុំក៏ទិញអាហារថ្ងៃត្រង់ឲ្យគេជំនួសវិញ។ ការធ្វើបែបនេះអាចនៅតែជាការលើកកម្ពស់ការយល់ឃើញបែប "កំពូលអ្នកឧបត្ថម្ភមកពីអឺរ៉ុប" ដែលខ្ញុំព្យាយាមបញ្ចៀសមិនឲ្យមាន។ (ជនជាតិអូស្ត្រាលី អាយុ៤០ឆ្នាំ)

បញ្ហាសីលធម៌ដែលអ្នកចូលរួមនេះលើកឡើង (ដោយប្រយោល) ពីកត្តាចិត្តសាស្ត្របែប "កំពូលអ្នកឧបត្ថម្ភមកពីអឺរ៉ុប" ត្រូវបានរៀបរាប់កាន់តែច្បាស់ដោយអ្នកចូលរួមម្នាក់ទៀតដែលដំណាលពីការធ្វើដំណើរកំសាន្តរបស់នាងមកកាន់តំបន់នេះថា ៖

ស្ត្រីមួយចំនួននៅក្នុង...ក្រុមបានទិញសម្លៀកបំពាក់ និងសម្ភារៈសិក្សាចែកឲ្យកុមារក្នុងភូមិបណ្តែតទឹក (ប៉ុន្តែ) មគ្គុទ្ទេសក៍ទេសចរបានចែករបស់ទាំងនេះឲ្យកុមារក្នុងរបៀប (ឲ្យកុមាររុញគ្នា និងលោតដើម្បីចាប់យកអំណោយនេះ) ដែលធ្វើឲ្យខ្ញុំមិនស្រួលចិត្តសោះ។ (ជនជាតិអាមេរិក អាយុ៤០ឆ្នាំ)

បើទោះជាអន្តរសកម្មភាពបែបនេះធ្វើឡើងក្នុងបំណងល្អ បើតាមពាក្យសម្តីទាំងនេះ វាបង្ហាញច្បាស់ថាអ្នកចូលរួមនៅតែមានមន្ទិល ឬកង្វល់ពីឥទ្ធិពលនៃអន្តរសកម្មភាពរបស់ពួកគេលើកុមារ។ នៅក្នុងករណីចុងក្រោយខាងលើ វាមានលក្ខណៈច្បាស់ដែលអ្នកតំណាងឧស្សាហកម្មទេសចរណ៍ដូចជាមគ្គុទ្ទេសក៍ទេសចរ ត្រូវបានពិនិត្យពិច័យដោយភ្ញៀវទេសចរពីឥទ្ធិពលដែលពួកគេមានចំពោះសហគមន៍ក្នុងស្រុក និងជាពិសេសលើកុមារ និងត្រូវបានរំពឹងដោយភ្ញៀវទេសចរឲ្យបង្ហាញនូវការយល់ដឹងពីវប្បធម៌នៅពេលដើរតួជាអន្តរការីរវាងក្រុមភ្ញៀវទេសចរ និងប្រជាជនក្នុងស្រុក។ ទោះជាយ៉ាងណាក៏ដោយ ភាពស្ទាក់ស្ទើរ ឬមន្ទិលពីឥរិយាបថល្អបំផុតដែលត្រូវប្រព្រឹត្តចំពោះកុមារបង្ហាញពីគោលគំនិតកាន់តែរឹងមាំនៅក្នុងការពិភាក្សារបស់អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះចំពោះការឆ្លើយតបរបស់ពួកគេចំពោះកុមារដែលកំពុងសុំទាន ឬលក់អ៊ីវ៉ាន់នៅក្នុងតំបន់នេះ។

# ការជួបប្រទះកុមារសុំទាន ឬលក់អ៊ីវ៉ាន់

ក្នុងចំណោមអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិទាំង ៣១៦នាក់ ដែលឆ្លើយនឹងសំណួរស្តីពីការជួបប្រទះរបស់ពួកគេជាមួយកុមារសុំទាន មានអ្នកចូលរួម៧៨,៧% បានលើកឡើងថាពួកគេមិនបានឲ្យលុយដល់កុមារ ឬមនុស្សវ័យក្មេងសុំទាន នៅពេលពួកគេស្នាក់នៅក្នុងតំបន់នេះទេ។ ភាគច្រើននៃអ្នកដែលចៀសវាងការឲ្យលុយទៅកុមារសុំទានពន្យល់ពីសកម្មភាពរបស់ពួកគេដោយរំលឹកពីដំណោះស្រាយនិរន្តរភាព និងក្តីកង្វល់ ព្រមទាំងចង់កាត់បន្ថយការកេងប្រវ័ញ្ចលើកុមារដែលអាចកើតមាន។ ភាគច្រើននៃអ្នកចូលរួមមានការយល់ដឹងខ្ពស់អំពីចំណុចដែលថាបើកុមារនៅដើរសុំទានតាមចិញ្ចើមថ្នល់ នោះពួកគេច្រើនតែមិនអាចទៅរៀននោះទេ និងអាចងាយរងគ្រោះពីការកេងប្រវ័ញ្ច ឬរំលោភបំពាន។ អ្នកចូលរួមភាគច្រើនក៏និយាយដែរថាការសុំទានមិនបានបង្កើនអំណាចដល់កុមារ ឬមិនមែនជាមធ្យោបាយល្អសម្រាប់បញ្ចប់វដ្តនៃភាពក្រីក្រនោះទេ។ អ្នកចូលរួមមួយចំនួនក៏បានលើកឡើងពីចំណុចដែលពួកគេគិតថាជាជម្រើសដែលប្រសើរជាងនេះដូចជាការបរិច្ចាគលុយដល់អង្គការសប្បុរសធម៌ក្នុងស្រុក ឬឲ្យអាហារដល់កុមារវិញ។ គេឧស្សាហ៍ឃើញការលើកឡើងដូចខាងក្រោម៖

ខ្ញុំគិតថាការឲ្យលុយទៅអ្នកសុំទានធ្វើឲ្យបញ្ហាចេះតែបន្តទៅមុខ។ ទោះយ៉ាងណាក៏កុមារជារឿយៗមិនត្រូវបានអនុញ្ញាតឲ្យទុកលុយនេះទេ។ បើអាច ខ្ញុំនឹងបរិច្ចាគលុយទៅឲ្យអ

ង្គការសប្បុរសធម៌ ឬគម្រោងសហគមន៍ក្នុងស្រុកជំនួសវិញ។ (ស្រ្តី ជនជាតិអូស្ត្រាលី អាយុ៣៦ឆ្នាំ)

ខ្ញុំបានទិញអាហារពេលល្ងាចឲ្យកុមារជាច្រើនដែលឈរនៅតាមចិញ្ចើមថ្នល់។ ខ្ញុំចង់ឲ្យចំណីអាហារដល់ពួកគេជាជាងឲ្យលុយទៅពួកគេ ព្រោះថាយើងមិនដឹងថាគេនឹងយកលុយ នោះទៅធ្វើអ្វីទេ។ (ស្ត្រី ជនជាតិញូវហ្សីលែន អាយុ៤៦ឆ្នាំ)

ខ្ញុំបានទិញស្បែកជើងពីផ្សារប្រចាំតំបន់មួយឲ្យកុមាររស់តាមចិញ្ចើមថ្នល់ចំនួន៦នាក់។ ខ្ញុំបាននិយាយជាមួយពួកគេពីការដែលពួកគេចង់ទៅរៀននៅសាលា។ កុមារភាគច្រើនបាននិយាយថាពួកគេទៅរៀននៅសាលា ឬថាលុយដែលអ្នកឲ្យពួកគេនឹងជួយដល់ការអប់រំរបស់ពួកគេ ប៉ុន្តែខ្ញុំគិតថាចំណុចនេះគួរឲ្យសង្ស័យណាស់។ (ស្រ្តី ជនជាតិអារ៉ាប់រួមអេមីរ៉ែត អាយុ២៧ឆ្នាំ)

(ខ្ញុំ) ជឿថាការឲ្យលុយទៅកុមារសុំទាននឹងបន្តឲ្យពួកគេស្ថិតក្នុងស្ថានភាពងាយរងគ្រោះ... (ខ្ញុំ) យល់ដឹងថាកុមារ និងមនុស្សវ័យក្មេងត្រូវបានជួញដូរឲ្យធ្វើជាអ្នកសុំទាន។ (ស្រ្តី ជនជាតិកម្ពុជា អាយុ៣៣ឆ្នាំ)

ម្យ៉ាងវិញទៀត ចំពោះអ្នកដែលបានរាយការណ៍ថាបានឲ្យលុយទៅកុមារដែលសុំទាន (១៧,៥%នៃអ្នកចូលរួម) ភាគច្រើនហាក់សម្គាល់ថាទង្វើនេះប្រហែលមិនមែនជាសកម្មភាពល្អបំផុតនោះទេ (ក្នុងរយៈពេលវែង) ប៉ុន្តែនិយាយថាពួកគេធ្វើបែបនេះដោយសារក្តីអាណិត ពីព្រោះវា "លំបាកពេក" ក្នុងការមិនឲ្យលុយដល់កុមារទាំងនោះ និង/ឬពីព្រោះពួកគេចង់ជួយកុមារទាំងនោះ។

"ខ្ញុំគិតថាការឲ្យលុយទៅអ្នកសុំទានធ្វើឲ្យបញ្ហាចេះតែបន្តទៅមុខៗ ទោះយ៉ាងណា ក៏កុមារជារឿយៗមិនត្រូវបានអនុញ្ញាតឲ្យទុកលុយនេះទេៗ បើអាច ខ្ញុំនឹងបរិច្ចាគលុយទៅឲ្យអង្គការសប្បុរសធម៌ ឬគម្រោងសហគមន៍ម្ចាស់ស្រុកជំនួសវិញៗ"

ឧទាហរណ៍អ្នកចូល រួមជាស្រ្តីម្នាក់បាននិយាយថានាងបានឲ្យលុយ ពីព្រោះនាង "មិនអាចទប់ចិត្ត" ខ្លួនឯងបាន ហើយអ្នក ចូលរួមម្នាក់ទៀតរាយការណ៍ថាបានឲ្យលុយ ពីព្រោះ "ពួកគេមើលទៅកខ្វក់ និងគ្មានអាហារហូបធ្វើឲ្យ ខ្ញុំចង់ឲ្យលុយទៅពួកគេ"។ ប្រហែលដូចដែលគេឧស្សាហ៍ឮបំផុត អ្នកចូលរួមជាស្រ្តីម្នាក់និយាយថានាងតែងឲ្យលុយជារឿយៗ ដោយទទួលស្គាល់ថាស្របពេលជាមួយគ្នានោះ "ខ្ញុំឮគេថាការឲ្យលុយនេះនឹងធ្វើ ឲ្យស្ថានភាពកាន់តែធ្ងន់ធ្ងរ ហេតុនេះអ្នកតែងតែមាន... មន្ទិលនៅពេលអ្នកឲ្យលុយទៅពួកគេ គឺអ្នកមិនមែនកំពុងជួយពួកគេនោះទេ"។

ការលើកឡើងទាំងនេះបង្ហាញថាអ្នកចូលរួមជាច្រើនចង់ជួយ ប៉ុន្តែអាចមិនច្បាស់ និងមិនអាចសម្រេចចិត្តបានថាត្រូវជួយយ៉ាងណាទើបល្អបំផុត។ អ្វីដែលកាន់តែស្មុគស្មាញទៅទៀតគឺ ចម្លើយទាក់ទងនឹងថាតើអ្នកចូលរួមបានទិញ អ្វីវ៉ាន់ពីកុមារ ឬមនុស្សវ័យក្មេងដែលជាអ្នកលក់ ដែរឬយ៉ាងណា។ បើទោះជាភាគច្រើននៃអ្នកចូលរួមចៀសវាងមិនមានអន្តរសកម្មភាពជាមួយកុមារក្នុងរបៀបបែបនេះ ពួកគេជាទូទៅមិនសូវពិបាកចំពោះបញ្ហានេះដូចជាកុមារ សុំទានទាំងនោះទេ។ ត្រង់ចំណុចនេះ ត្រឹមតែ៥៣,២% នៃអ្នកចូលរួមប៉ុណ្ណោះឆ្លើយថា ទេ នៅពេលត្រូវបានសួរថាតើពួកគេបាន ទិញទំនិញ ឬសេវាកម្មពីកុមារឬទេ ហើយ៣៤,៩%ឆ្លើយថា បាទ/ចាស។ ក្នុងចំណោមអ្នកដែលឆ្លើយថា ទេ ភាគច្រើនបង្ហាញថាពួកគេបដិសេធមិនទិញទំនិញ ឬសេវាកម្មពីកុមារ ពីព្រោះពួកគេដឹងថាការទិញទំនិញ ឬសេវាកម្មពីកុមារកាត់

បន្ថយឱកាសរបស់កុមារក្នុងការទៅរៀន និងអាចនាំឲ្យពួកគេត្រូវបានកេងប្រវ័ញ្ច។ ជាថ្មីម្តងទៀត ពួកគេក៏បានបង្ហាញថាពួកគេពិបាកចិត្តចំពោះចំណុចនេះ។ ហេតុនេះហើយគេឧស្សាហ៍ឃើញការលើកឡើងដូចខាងក្រោម ៖

> ការជួយកុមាររស់នៅតាមចិញ្ចើមថ្នល់ជារឿយៗគឺជាការសំរេចចិត្តដ៏លំបាកទាក់ទងនឹងបញ្ហាសីលធម៌។ អ្នកដឹងថាកុមារទាំងនេះគួរតែទៅសាលារៀន និងមិនគួរមកនៅតាមចិញ្ចើមថ្នល់សុំទាន ឬលក់អីវ៉ាន់នោះទេ។ ក៏ប៉ុន្តែ វាពិតជាការលំបាកណាស់ក្នុងការដើរចេញពីពួកគេ ដោយដឹងថាពួកគេអាចចូលដេកដោយគ្មានអាហារក្នុងពោះនៅយប់នោះ។ (ស្ត្រី ជនជាតិអេស្ប៉ាញ អាយុ៣២ឆ្នាំ)

ម៉្យាងវិញទៀត ចំពោះអ្នកដែលបានទិញអីវ៉ាន់ពីអ្នកលក់ជាកុមារ/មនុស្សវ័យក្មេងមានហេតុផលផ្សេងៗគ្នាក្នុងការធ្វើបែបនេះ។ ជាធម្មតា ការទិញអីវ៉ាន់ពីកុមារត្រូវបានពន្យល់ថាជាការឆ្លើយតបចំពោះការទទូចរបស់
កុមារ ពីព្រោះពួកគេគិតថាតាមរយៈការធ្វើបែបនេះ គឺពួកគេកំពុងជួយ ពីព្រោះពួកគេមានក្តីអាណិត ឬក្នុងករណីខ្លះគឺគ្រាន់តែដោយសារទំនិញ/សេវាកម្មដែលលក់/ផ្តល់ជូននោះគឺជា "តម្រូវការចាំបាច់" ឬមិនអាចរកទិញបានពីអ្នកដទៃ (ពោលគឺពីមនុស្សពេញវ័យ)។ ការលើកឡើងដូចតទៅគឺជាឧទាហរណ៍ ៖

> ខ្ញុំបានទិញអីវ៉ាន់ពីកុមារនៅចុងសប្តាហ៍ បន្ទាប់ពីខ្ញុំសួរពួកគេដោយផ្ទាល់អំពីការទៅសាលារៀន។ ប្រសិនបើពួកគេចាំបាច់ត្រូវធ្វើការដើម្បីផ្គត់ផ្គង់គ្រួសារពួកគេដែលមានចំណូលខ្វះខាត និងដើម្បីអនុញ្ញាតឲ្យពួកគេបានទៅរៀននៅថ្ងៃធម្មតាខុសពីចុងសប្តាហ៍ ខ្ញុំមានអារម្មណ៍ថារឿងនេះជាការសមរម្យ។ (ស្ត្រី ជនជាតិអូស្ត្រាលី អាយុ៣៥ឆ្នាំ)
>
> ខ្ញុំមានអារម្មណ៍អាណិតពួកគេ ហើយចង់ជួយពួកគេ។ ហើយពួកគេក៏ទទូចខ្លាំងណាស់ដែរ។ (ស្ត្រី ជនជាតិអង់គ្លេស អាយុ៣៧ឆ្នាំ)
>
> (ខ្ញុំ)ចង់ជួយពួកគេ។ រាល់ដងខ្ញុំតែងទិញទំនិញនៅច្រកចេញពីកន្លែងភ្ញៀវទេសចរចូលទស្សនាដូចដែលខ្ញុំធ្លាប់ចាយលុយនៅទីនោះ តែឥឡូវ (ខ្ញុំទិញអីវ៉ាន់ពីកុមារ) ហើយចែកឲ្យអ្នកដទៃ។ (ស្ត្រី ជនជាតិអូស្ត្រាលី អាយុ៣៨ឆ្នាំ)
>
> ពួកគេនិយាយថាពួកគេទៅសាលារៀននៅពេលព្រឹក ហើយធ្វើការនៅពេលរសៀល។ (ខ្ញុំ) គិតថាការជួយរកចំណូលចិញ្ចឹមជីវិតសម្រាប់គ្រួសារគឺជារឿងល្អ។ (ស្ត្រី ជនជាតិអូស្ត្រាលី អាយុ៤៤ឆ្នាំ)

អ្នកចូលរួមទាំងនេះពិតជាមានការពិចារណាហ្មត់ចត់អំពីជម្រើសប្រើប្រាស់របស់ពួកគេ នៅពេលធ្វើដំណើរ។ ពួកគេរាយការណ៍ថាបានព្យាយាមយ៉ាងយកចិត្តទុកដាក់ក្នុងការស្វែងយល់ពីជីវិតរបស់កុមារដែលពួកគេបានប្រាស្រ័យទាក់ទងជាមួយ ហើយពិតជាបានចំណាយពេលមិនត្រឹមតែស្វែងយល់ពីចម្ងល់ទាំងនេះនោះទេ ថែមទាំងវាយតម្លៃពីភាពមានកម្រិតនៃជម្រើសដែលមានសម្រាប់ពួកគេ និងឥទ្ធិពលដែលអាចមាននៃជម្រើសរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ជារួមអ្នកចូលរួមជារឿយៗនៅតែមិនមានភាពប្រាកដប្រជាអំពីវិធីល្អបំផុតដើម្បីឆ្លើយតបចំពោះកុមារលក់ដូរ ឬសុំទាន។ ភាពមិនប្រាកដប្រជានេះបង្ហាញឡើងផងដែរតាមរយៈការពិភាក្សារបស់អ្នកចូលរួមអំពីរបៀបដែលពួកគេបានឆ្លើយតបចំពោះករណីការរំលោភបំពាន និងកេងប្រវ័ញ្ចដែលពួកគេបានឃើញនៅពេលស្នាក់នៅក្នុងតំបន់នេះ។

# ការជួបប្រទះការកេងប្រវ័ញ្ច/រំលោភបំពានលើកុមារនៅពេលធ្វើដំណើរ

នៅពេលត្រូវបានសួរថាតើពួកគេមានឃើញរឿងអ្វីមួយដែលធ្វើឲ្យពួកគគេិតថា កុមារ ឬមនុស្សវ័យក្មេងអាចកំពុងជួបប្រទះ ឬប្រឈមនឹងហានិភ័យនៃការរំលោភបំពាន ឬការកេងប្រវ័ញ្ចដែរឬទេ ៥៧,១% នៃអ្នកចូលរួមនិយាយថា បាទ/ចាស។ ភាគច្រើននៃការរំលោភបំពាន ឬកេងប្រវ័ញ្ចសំដៅលើកុមារលក់ទំនិញ ឬសុំទាន និងត្រូវបានប្រើដោយមនុស្សពេញវ័យ (ក្នុងករណីខ្លះគឺម្ដាយឪពុករបស់កុមារទាំងនោះ) ឲ្យដើរតួធ្វើយ៉ាងណាឲ្យភ្ញៀវទេសចរអាណិត។ អ្នកចូលរួមខ្លះទៀតនិយាយពីការរំលោភសិទ្ធិ ក្នុងការទទួលបានការអប់រំ និង/ឬកុមារភាពរបស់កុមារ ហើយគួរឲ្យចាប់អារម្មណ៍គឺមានអ្នកចូលរួមមួយចំនួនតូចយល់ថាការធ្វើអាជីវកម្មពាក់ពន្ធ័នឹងកុមារ និងវប្បធម៌ក្នុងស្រុកជាធាតុផ្សំដែលមានបញ្ហារបស់ឧស្សាហកម្មទេសចរណ៍ (ដូចជារាយការណ៍ថាកុមារត្រូវបានប្រាប់ឲ្យ "ស្លៀកពាក់ក្នុងសម្លៀកបំពាក់ប្រពៃណីដើម្បីថតរូប" និងកុមារក្នុងមណ្ឌលកុមារកំព្រាត្រូវបាន "យកចេញពីសាលារៀនឲ្យមកសម្ដែង" ឲ្យភ្ញៀវទេសចរទស្សនា គឺជាឧទាហរណ៍នៃការរំលោភបំពាន)។ អ្នកចូលរួមជាច្រើនក៏និយាយពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដោយលើកឡើងពីពេលដែលពួកគេបានឃើញ (ជាធម្មតា) ក្មេងស្រីៗ (និងជួនកាលក្មេងប្រុសៗ) នៅជាមួយបុរស "ជនដែលមកពីលោកខាងលិច" ចំណាស់ ៖ នេះជាស្ថានភាពដែលពួកគេយល់ថាជាបញ្ហាដ៏ធ្ងន់ធ្ងរ។ គួរឲ្យចាប់អារម្មណ៍នោះគឺ គ្រប់អ្នកចូលរួមទាំងអស់ដែលពិភាក្សាពីការបានឃើញប្រភេទនៃការកេងប្រវ័ញ្ចទាំងនេះបានលើកឡើងថាវាធ្វើឲ្យពួកគេមានអារម្មណ៍ខ្ពើមរអើម ក្រៀមក្រំ មានកង្វល់ ឬព្រួយបារម្ភ មិនដឹងថាត្រូវជួយបែបណា បន្ទោសខ្លួនឯង ខឹង និង/ឬអន្ទះសារ ដោយសង្កេតឃើញឧទាហរណ៍ដូចជា ៖

> "ជារឿយៗ អ្នកនឹងឃើញមនុស្សពេញវ័យម្នាក់លាក់ខ្លួន (ក្បែរនោះ) ជំរុញឲ្យកុមារជជែកជាមួយភ្ញៀវទេសចរៗ ជារឿយៗ ខ្ញុំចង់នៅជាមួយកុមារទាំងនោះឲ្យយូរបំផុតតាមដែលអាចធ្វើបាន ក្ដីសង្ឃឹមខុសរបស់ខ្ញុំ (គឺ) ជឿថាការធ្វើបែបនេះនឹងរក្សាពួកគេឲ្យនៅឆ្ងាយពីអ្នកបញ្ជារបស់ពួកគេៗ គ្រប់ពេលខ្ញុំមានអារម្មណ៍ថាមិនដឹងថាជួយបែបណានោះទេៗ"

ជារឿយៗ អ្នកនឹងឃើញមនុស្សពេញវ័យម្នាក់លាក់ខ្លួន (ក្បែរនោះ) ជំរុញឲ្យកុមារជជែកជាមួយភ្ញៀវទេសចរ។ ជារឿយៗ ខ្ញុំចង់នៅជាមួយកុមារទាំងនោះឲ្យយូរបំផុតតាមដែលអាចធ្វើបាន ក្ដីសង្ឃឹមខុសរបស់ខ្ញុំ (គឺ) ជឿថាការធ្វើបែបនេះនឹងរក្សាពួកគេឲ្យនៅឆ្ងាយពីអ្នកបញ្ជារបស់ពួកគេ។ គ្រប់ពេល ខ្ញុំមានអារម្មណ៍ថាមិនដឹងថាជួយបែបណានោះទេ។
(មិនបានផ្ដល់ព័ត៌មានពីភេទ សញ្ជាតិ និងអាយុ)

ជំនួសឲ្យការទៅសាលារៀន កុមារជាច្រើននៅតាមចិញ្ចើមថ្នល់ និងឆ្នេរសមុទ្រលក់សៀវភៅ ខ្សែដៃ ផ្លែឈើ ។ល។ ខ្ញុំចូលចិត្តនិយាយជាមួយពួកគេ ហើយពួកគេចូលចិត្តអនុវត្តភាសាអង់គ្លេស ប៉ុន្តែខ្ញុំមានអារម្មណ៍មិនល្អដែលពួកគេត្រូវបានម្ដាយឪពុកពួកគេបង្ខំឲ្យធ្វើការ ហើយបាត់បង់ឱកាសទៅទទួលការអប់រំបានត្រឹមត្រូវនៅសាលារៀន។ (ស្ត្រី ជនជាតិអូស្ត្រាលី អាយុ២៦ឆ្នាំ)

ចំនួនបុរសវ័យចំណាស់នៅលើវធ្វើឲ្យខ្ញុំមានអារម្មណ៍មិនល្អ និងលែងសូវសប្បាយជាមួយការធ្វើដំណើរ។ (ស្ត្រី ជនជាតិញូវហ្ស៊ីលែន អាយុ៤៥ឆ្នាំ)

(ខ្ញុំបានឃើញ) ក្មេងស្រី (អាយុ៥-៦ឆ្នាំ) លក់វត្ថុអនុស្សាវរីយ៍។ (ខ្ញុំ) ចេះតែគិតថាពិតជាមានមនុស្សនៅពីក្រោយដែលបង្ខំឲ្យនាងធ្វើបែបនេះ និងរំលោភបំពានលើនាងមិនថានាងលក់វត្ថុអនុស្សាវរីយ៍ដាច់ ឬក៏អត់ក៏ដោយ។ ខ្ញុំសម្រេចចិត្តថាមិនទិញអ្វីវ៉ាន់ពីនាង ប៉ុន្តែខ្ញុំនៅតែនឹកឃើញរឿងនោះហាក់នៅស្រស់ៗនឹងភ្នែក ហើយវាធ្វើឲ្យខ្ញុំខូចចិត្តបន្ទាប់មកយំជាច្រើនម៉ោង។ (ស្ត្រី ជនជាតិអាមេរិក អាយុ៣០ឆ្នាំ)

(ការឃើញ) នារីវ័យក្មេងត្រូវបានកេងប្រវ័ញ្ចក្នុងទេសចរណ៍ផ្លូវភេទ ពិតជាធ្វើឲ្យ(ខ្ញុំ) មានអារម្មណ៍ស្អប់ខ្ពើម ហើយបានចាកចេញពី ទីនោះឆាប់ជាងរយៈ  ពេលដែលបានគ្រោងទុកដោយសារ តែរឿងនេះ។ (ស្ត្រី ជនជាតិអាមេរិក អាយុ៣០ឆ្នាំ)

អារម្មណ៍ខឹង អន្ទះសារ និង/ឬមានកង្វល់ពិតជាផ្សារភ្ជាប់នឹងចំណុចដែលស្ទើរតែពាក់កណ្តាល(៤៩,៥%) នៃអ្នកឆ្លើយតបយល់ថាពួកគេត្រូវចូលរួមទទួលខុសត្រូវ ចំពោះកុមារ និងមនុស្សវ័យក្មេងក្នុងស្រុក ក្នុងពេលធ្វើដំណើរ ប៉ុន្តែត្រឹមតែ១៩,៥%នៃអ្នកឆ្លើយតបយល់ថាពួកគេមានព័ត៌មានគ្រប់គ្រាន់ដើម្បីការពារកុមារ និងមនុស្សវ័យក្មេងក្នុងស្រុកដែលពួកគេបានជួបនៅកន្លែងសាធារណៈ។ ចំណុចនេះត្រូវបានបង្ហាញនៅក្នុងការលើកឡើងពីភ្ញៀវទេសចរដែលត្រូវបានស្ទាបស្ទង់មតិដូចតទៅ៖

ខ្ញុំយល់ថាខ្ញុំត្រូវចូលរួមទទួលខុសត្រូវ ប៉ុន្តែខ្ញុំមិនដឹងថាតើខ្ញុំអាចធ្វើអ្វីបានដើម្បីឲ្យវាត្រូវនោះទេ។ (ស្ត្រី ជនជាតិអូស្ត្រាលី អាយុ៣៨ឆ្នាំ)

ដោយមិនដឹងពីរបៀបឈ្លាសវៃដើម្បីដោះស្រាយ (បញ្ហា) ខ្ញុំជារឿយៗយល់ថាខ្លួនឯងហាក់ដូចគ្រាន់តែជាអ្នកចាំសង្កេតប៉ុណ្ណោះ។ (បុរស ជនជាតិអាមេរិក អាយុ៣៧ឆ្នាំ)

"ខ្ញុំយល់ថាខ្ញុំត្រូវចូលរួមទទួលខុសត្រូវ ប៉ុន្តែខ្ញុំមិនដឹង ថាតើខ្ញុំអាចធ្វើអ្វីបាន ដើម្បីឲ្យវាត្រូវនោះទេ។"

ខ្ញុំមានព័ត៌មានខ្លះស្តីពីកន្លែងដែលអាចទទួលបានការជួយបើ (ខ្ញុំ) ត្រូវការ ប៉ុន្តែ (វា) មិនដែលគ្រប់គ្រាន់នោះទេ។ (ស្ត្រី ជនជាតិអូស្ត្រាលី អាយុ៥៤ឆ្នាំ)

ខ្ញុំយល់ថាខ្ញុំចង់ធ្វើឲ្យបានច្រើនជាងនេះដោយសារខ្ញុំ ដឹងពី...ស្ថានភាពនេះ។ ខ្ញុំគ្រាន់តែមិនមានធនធាន ជំនាញ និងចំណេះដឹងចាំបាច់ដើម្បីធ្វើវា។ (ស្ត្រី ជនជាតិហ្វាំងឡង់ អាយុ២០ឆ្នាំ)

បើទោះជាអ្នកចូលរួមមួយចំនួនរាយការណ៍ថា បានអនុវត្តសកម្មភាពដើម្បីជួយកុមារដែលត្រូវការការជួយ (ក្នុងករណីជាច្រើន ការរាយការណ៍ទៅឲ្យប៉ូលីស និងកាន់តែញឹកញាប់ទៅទៀត គឺរាយការណ៍ទៅឲ្យបុគ្គលិកនៅតាមអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសប្បុរសធម៌[20]) ជាពិសេសទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក៏អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនេះជារឿយៗរាយការណ៍ថាពួកគេមិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីជួយ ឬថាការរាយការណ៍របស់ពួកគេមិនត្រូវបាននរណាជួយអើពើនោះឡើយ។ ការលើកឡើងតទៅបង្ហាញពីនិន្នាការនេះ ៖

20 ឧទាហរណ៍ អ្នកចូលរួមម្នាក់រាយការណ៍ថាបាន "ឃើញកុមារអនាថាតូចម្នាក់នៅតាមឆ្នេរសមុទ្រដែលកំពុងគ្រុនក្តៅខ្លាំង"។ អ្នកចូលរួមនេះបាននៅរង់ចាំជាមួយកុមារ និង "ទូរស័ព្ទទៅបណ្តាញសុវត្ថិភាពកុមារឲ្យមកជួយយកកុមារទៅរកវេជ្ជបណ្ឌិត"។

> ខ្ញុំបានឃើញកុមារពីរនាក់នៅហាងកាហ្វេជាមួយបុរសៗដែលប្រាប់ខ្ញុំថាកុមារទាំងនោះជាកូនរបស់មិត្តស្រីពួកគេ។ កុមារទាំងនោះពិតជាមិនសប្បាយចិត្តទេ ហើយខ្ញុំមិនជឿរឿងនោះទេ។ ខ្ញុំគ្មានឱកាសនិយាយជាមួយកុមារទាំងនោះដោយផ្ទាល់ទេ ហើយចេះតែភ័យមិនហ៊ាននៅក្បែរនោះទៀត ខ្ញុំយល់ថាខ្ញុំមិនអាចរាយការណ៍ករណីនេះទៅឲ្យប៉ូលីសទេ។ ខ្ញុំនៅតែឆ្ងល់អំពីកុមារទាំងពីរនាក់នោះ ហើយសង្ឃឹមថាពួកគេមិនមានបញ្ហា។ (ស្ត្រី ជនជាតិអូស្ត្រាលី អាយុ៣៥ឆ្នាំ)
>
> ...យើងបានឃើញកុមារីក្នុងស្រុកម្នាក់នៅជាមួយបុរសស្បែកសចំណាស់ម្នាក់។ យើងមានកង្វល់ថា នាងអាចប្រឈមនឹងការរំលោភបំពាន/កេងប្រវ័ញ្ច ហើយរាយការណ៍រឿងនេះទៅឲ្យប៉ូលីស។ ពួកយើងពួកយើងមិនច្បាស់ថាប៉ូលីសនឹងឆ្លើយតបចំពោះការរាយការណ៍របស់ពួកយើងឲ្យបានច្រើនបំផុតតាមដែលពួកគេអាចធ្វើបានឬយ៉ាងណានោះទេ។ (ស្ត្រី ជនជាតិអូស្ត្រាលី អាយុ២៤ឆ្នាំ)
>
> ខ្ញុំបានឃើញបុរសជនដែលមកពីលោកខាងលិចចំណាស់ម្នាក់ជាមួយកុមារីជាច្រើននៅឆ្នេរសមុទ្រ។ វាមើលទៅគួរឲ្យសង្ស័យ ហើយខ្ញុំមានអារម្មណ៍មិនស្រួល។ ខ្ញុំបានព្យាយាមទូរស័ព្ទទៅបណ្តាញទូរស័ព្ទសុវត្ថិភាពកុមារ ប៉ុន្តែខ្ញុំមិនអាចទូរស័ព្ទចូលសោះ ហេតុនេះខ្ញុំក៏រាយការណ៍រឿងនេះទៅឲ្យប៉ូលីស (ដែលនិយាយថាពួកគេមិនអាចធ្វើអ្វីបានទេ លុះត្រាតែបុរសនោះនាំកុមារីចូលបន្ទប់សណ្ឋាគារ)។ ខ្ញុំខឹង និងអន្ទះសារជាខ្លាំងដោយមិនដឹងថាត្រូវជួយដោយរបៀបណា។ (ខ្ញុំបានជួប) រឿងដូចគ្នានៅគោលដៅទេសចរណ៍បន្ទាប់របស់ខ្ញុំ។ បុរសជនដែលមកពីលោកខាងលិចចំណាស់ម្នាក់ជាមួយកុមារីជាច្រើន មាននៅគ្រប់ទីកន្លែង នៅរង្គសាលផឹកស្រា-ល- ប៉ុន្តែខ្ញុំមិនដឹងថាត្រូវជួយដោយរបៀបណា។ ខ្ញុំពិបាកនឹងប្រឈមនឹងរឿងនេះ ហើយវាប៉ះពាល់ដល់អារម្មណ៍ខ្ញុំជាខ្លាំង ហើយខ្ញុំនឹងមិនត្រឡប់មកទីនេះទៀតទេ។
> (ស្ត្រី ជនជាតិអូស្ត្រាលី អាយុ៣៦ឆ្នាំ)

ដូចអ្នកចូលរួមនេះដែរ អ្នកឆ្លើយតបមួយចំនួនបង្ហាញថាការជួបប្រទះព្រឹត្តិការណ៍ដែលពួកគេគិតថាទាក់ទង នឹងការកេងប្រវ័ញ្ច ឬរំលោភបំពានលើកុមារ និងមនុស្សវ័យក្មេងប៉ះពាល់ជាអវិជ្ជមាន ដល់ការសម្រាកវិស្សមកាលរបស់ពួកគេហើយថាពួកគេអាចកាត់បន្ថយរយៈពេលស្នាក់នៅកន្លែង ជាក់លាក់ ឬមិនត្រឡប់ទៅកន្លែងនោះវិញដោយសារតែជួបរឿងទាំងនេះ។ ទោះជាយ៉ាងនេះក្តី ក៏អ្នកចូលរួមជាច្រើនបានលើកឡើងថាពួកគេមិនបានរាយការណ៍ពីកង្វល់របស់ពួកគេ (២២,២%) ឬថានៅពេលដែលពួកគេរាយការណ៍ ក៏ពួកគេភាគច្រើនប្រាប់ពីរឿងនេះដល់អ្នកដំណើរផ្សេងទៀត (៦១,៣%)។ បើទោះជាប្រការនេះជួនកាលបណ្តាលមកពីកង្វះការជឿទុកចិត្តលើអាជ្ញាធរមូលដ្ឋាន ជួនកាលវាក៏អាចបណ្តាលមកពីការមិនដឹងថាត្រូវរាយការណ៍រឿងនេះទៅនរណា(ផ្សេងទៀត)។ ចំណុចចុងក្រោយនេះ ស្របគ្នាទៅនឹងលទ្ធផលដែលថា ៤៨,២%នៃអ្នកចូលរួមបង្ហាញថាពួកគេមិនបានទទួលព័ត៌មានពីរបៀបការពារកុមារ និងមនុស្សវ័យក្មេងក្នុងតំបន់នេះពីការរំលោភបំពាន/កេងប្រវ័ញ្ច មុនពេល ឬក្នុងអំឡុងពេលធ្វើដំណើររបស់ពួកគេ។ ក្នុងចំណោមអ្នកដែលទទួលបានព័ត៌មានបែបនេះ ត្រឹមតែ១៥,៦% ប៉ុណ្ណោះ

> "ខ្ញុំយល់ថាខ្ញុំចង់ធ្វើឲ្យបានច្រើនជាងនេះដោយសារខ្ញុំដឹងពី...ស្ថានភាពនេះៗ ខ្ញុំគ្រាន់តែមិនមានធនធាន ជំនាញ និងចំណេះដឹងចាំបាច់ដើម្បីធ្វើវា"

ដែលបានទទួលព័ត៌មានបែបនេះមុនពេលមកដល់កន្លែងគោលដៅរបស់ពួកគេ (អ្នកផ្សេងទៀតទទួលព័ត៌មានបែបនេះនៅកន្លែងគោលដៅ (២៧,១%) ឬនៅពេលពួកគេចាកចេញទៅវិញ(៤,៤%)។ លើសពីនេះទៅទៀត អ្នកចូលរួមមួយចំនួនដែលមិនបានរាយការណ៍ពីការកេងប្រវ័ញ្ច ឬរំលោភបំពានបង្ហាញថាពួកគេមិនយល់ថាពួកគេត្រូវមានការទទួលខុសត្រូវ ដោយនិយាយថាការទទួលខុសត្រូវក្នុងការថែរក្សាកុមារមនុស្សវ័យក្មេងក្នុងស្រុកនៅកន្លែងសាធារណៈគឺជាបន្ទុករបស់រដ្ឋាភិបាល/សមាជិកសភាមន្ត្រីច្បាប់ និងឬម្ដាយឪពុក។ លើសពីនេះ អ្នកចូលរួមមួយចំនួនយល់ថាវាមិនសមរម្យសម្រាប់ពួកគេក្នុងការវិនិច្ឆ័យទៅលើវប្បធម៌របស់អ្នកដទៃ ឬធ្វើអន្តរាគមន៍លើបញ្ហារបស់ប្រជាជនក្នុងស្រុក ឬថាវាអាចមានគ្រោះថ្នាក់ក្នុងការធ្វើអន្តរាគមន៍។ ជារឿយៗ អ្នក ចូលរួមបាននិយាយថាពួកគេស្ទាក់ស្ទើរក្នុងការប្រាប់អ្នកដទៃពីកង្វល់របស់ពួកគេ ពីព្រោះពួកគេមិនមានភាពប្រាកដប្រជាគ្រប់គ្រាន់អំពីរឿងដែលកំពុងកើតឡើង ហើយមនុស្សមួយចំនួនតូចលើកឡើងថាពួកគេមិនគិតថាការ រាយការណ៍ពីស្ថានភាពនោះនឹងនាំឲ្យមានការផ្លាស់ប្តូរនោះទេ ដោយចាត់ទុករឿងនោះថាជា "កត្តាដែលមិនអាចផ្លាស់ប្តូរបាន"។ ជាការពិតណាស់ នៅក្នុងករណីខ្លះ ការខកខានមិនបានរាយការណ៍ គឺអាចបណ្ដាលមកពីការយល់ឃើញថាភាគច្រើននៃឥរិយាបថបែបនោះ គឺជារឿងចៀសមិនផុត។ ឧទាហរណ៍ ៣៧,៤% នៃអ្នកឆ្លើយតបគិតថារឿងដែលកុមារ ឬមនុស្សវ័យក្មេងលក់វត្ថុអនុស្សាវរីយ៍ គឺត្រូវអត់ឱន ឬទទួលយកបានដោយសហគមន៍ក្នុងស្រុក។ អ្នកចូលរួមមួយចំនួនក៏គិតថាសហគមន៍ក្នុងស្រុកក៏អាចអត់ឱន ឬទទួលយកបាននូវរឿងដែលកុមារ ឬមនុស្សវ័យក្មេងដើរសុំទាន កុមារសម្តែងសិល្បៈឲ្យភ្ញៀវទេសចរទស្សនា ឬធ្វើការតាមសណ្ឋាគារ ឬភោជនីយដ្ឋាន។ បើទោះជាត្រឹមតែអ្នកចូលរួម ១,២% គិតថារឿងដែលកុមារ ឬមនុស្សវ័យក្មេងធ្វើការក្នុងរបររកស៊ីផ្លូវភេទក៏ត្រូវបានប្រជាជនម្ចាស់ស្រុក អត់ឱន ឬទទួលយក ២៨% នៃអ្នកឆ្លើយតបបង្ហាញថាពួកគេគិតថាការរួមផ្សំគ្នានៃឥរិយាបថកេងប្រវ័ញ្ចទាំងនេះ អាចបណ្ដាលមកពីប្រជាជនម្ចាស់ស្រុកចាត់ទុកវាថាជារឿងធម្មតា ឬមកពីប្រជាជនម្ចាស់ស្រុក (រួមទាំងអាជ្ញាធរមូលដ្ឋាន) មិនអើពើយកភ្នែកមើលតែម្តង (សូមមើលរូបភាពទី៦)។

> "ខ្ញុំបានឃើញ បុរសជនជាតិអឺរ៉ុបចំណាស់ម្នាក់ជាមួយកុមារីជាច្រើននៅឆ្នេរសមុទ្រ។ វាមើលទៅគួរឲ្យសង្ស័យ ហើយខ្ញុំមានអារម្មណ៍មិនស្រួល។ ខ្ញុំបានព្យាយាមទូរស័ព្ទទៅបណ្ដាញទូរស័ព្ទសុវត្ថិភាពកុមារ ប៉ុន្តែខ្ញុំមិនអាចទូរស័ព្ទចូលសោះ ហេតុនេះខ្ញុំក៏រាយការណ៍រឿងនេះទៅឲ្យប៉ូលីស (ដែលនិយាយថាពួកគេមិនអាចធ្វើអ្វីបានទេ លុះត្រាតែបុរសនោះនាំកុមារីចូលបន្ទប់សណ្ឋាគារ)។ ខ្ញុំខឹង និងអន្ទះសារជាខ្លាំងដោយមិនដឹងថាត្រូវជួយដោយរបៀបណា។"

ក្នុងករណីជាច្រើន អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិពិតជាញែកចេញពីគ្នារវាងការអត់ឱន និងការទទួលយកនៃឥរិយាបថទាំងនេះ ដោយលើកឡើងថាពួកគេគិតថាការអនុវត្តបែបនេះអាចនឹងត្រូវបានគេចាត់ទុកថាជារឿងធម្មតាយូរៗទៅ។ ជាពិសេស ពួកគេហាក់ដូចជាគិតថាការគិតថាជារឿងធម្មតានេះបានកើតឡើង ក៏ព្រោះតែតម្រូវការសេដ្ឋកិច្ច និងជួនកាលជាតម្រូវការចំណីអាហារ "ដើម្បីរស់" របស់គ្រួសារ និងសហគមន៍អាស្រ័យលើកុមាររកប្រាក់ចំណូលតាមរយៈវិស័យទេសចរណ៍។

ជារួមមានការយល់ឃើញយ៉ាងច្បាស់ក្នុងចំណោមអ្នកចូលរួមថា ឥរិយាបថទាំងនេះត្រូវបានអត់អោន ដោយសហគមន៍ម្ចាស់ស្រុក (ពីព្រោះពួកគេនៅស្ងៀម)។ ការយល់ឃើញបែបនេះ ពិតជាផ្សំនឹងការមានអារម្មណ៍ថាមិនអាច ជួយអ្វីបាន និងចិត្តអន្ទះសាររបស់ភ្ញៀវទេសចរ និងអាចជះឥទ្ធិពលលើឆន្ទះក្នុងការចូលរួម/ ធ្វើអន្តរាគមន៍នៅពេលមានករណីសង្ស័យពីការកេងប្រវ័ញ្ច និងរំលោភបំពាន។ ហេតុនេះការផ្តល់នូវព័ត៌មានបន្ថែមដល់អ្នកដំណើរអំពីការយល់ឃើញរបស់ប្រជាជនក្នុងស្រុកអំពីបញ្ហាទាំងនេះមានសារៈសំខាន់ណាស់។

រូបភាពទី៦ ៖ ចម្លើយចំពោះសំណួរ "តើកិច្ចការណាខ្លះក្នុងចំណោមកិច្ចការដូចតទៅ ដែលអ្នកគិតថាសហគមន៍ក្នុងស្រុកនៅតាមគោលដៅទេសចរណ៍ក្នុងតំបន់នេះគិតថាអាចអត់ឱន ឬអាចទទួលយកបាន?"



# ការយល់ឃើញ និងចំណាប់អារម្មណ៍របស់ភ្ញៀវទេសចរចំពោះ "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍"

ដោយផ្អែកលើលទ្ធផលជាច្រើននៃការស្ទាបស្ទង់មតិនេះ ដែលត្រូវបានពិភាក្សារួចមកហើយ វាមិនមែនជាការអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយ បើទោះជាអ្នកចូលរួមមួយចំនួនអាចមានការយល់ដឹងនៅមានកម្រិតពីឥទ្ធិពល នៃវិស័យទេសចរណ៍ទៅលើកុមារមុនពេលទៅទស្សនាតំបន់នេះ ក៏អ្នកចូលរួមជាច្រើន( ៨៤,៨% ) រាយការណ៍ថាចង់ដឹងព័ត៌មានបន្ថែមអំពីបញ្ហានេះមុនពេលពួកគេធ្វើដំណើរនាពេលអនាគត។ ជាការពិតណាស់ការលើកឡើងរបស់អ្នកចូលរួមមួយចំនួន ពិតជាបង្ហាញថា ប្រហែលជាអាចមានចំណុច ខ្វះខាតក្នុងការយល់ដឹងរបស់ពួកគេអំពីបញ្ហាក្រមសីលធម៌ក្នុងវិស័យទេសចរណ៍នៅពេលវាទាក់ទងនឹងកុមារ ( ដូចជាអ្នកចូលរួមជាច្រើនបានទៅទស្សនាមណ្ឌលកុមារកំព្រា )។ ដូចគ្នានេះដែរ ការយល់ឃើញរបស់ភ្ញៀវទេសចរចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ហាក់ដូចជានៅមានកម្រិតជាទិដ្ឋភាពរួមនៃបុរសស្បែកជនដែលមកពីលោកខាងលិចចំណាស់ដើរតួជាព្រានប្រមាញ់។ ប្រការនេះពិតជាធ្វើឲ្យភ្ញៀវទេសចរមើលមិនឃើញពីអ្នកដំណើរមិនមែនជនដែលមកពីលោកខាងលិចដែលចូលរួមក្នុងឥរិយាបថកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងចំណុចដែលថាស្ត្រីក៏អាចចូលរួមក្នុងសកម្មភាពបែបនេះបានដែរ។

វារិតតែមានការមើលស្រាលទៅទៀតនោះ គឺមានការយល់ឃើញថារឿងទាំងនេះកើតឡើងតែក្នុងករណីមានការជិះជាន់ខ្លាំង ឬបើតាមពាក្យសម្ដីរបស់អ្នកចូលរួមម្នាក់គឺ ផ្នែកមួយនៃវិស័យទេសចរណ៍ដែល "គួរឲ្យស្អប់ខ្ពើម" ប៉ុណ្ណោះ។

ទោះជាយ៉ាងណា ទស្សនៈរបស់ក្រុមអ្នកចូលរួមហាក់បង្ហាញពីកម្រិតសមស្របនៃការយល់ដឹងអំពីការទទួលខុសត្រូវ និងការសម្រេចចិត្តប្រកបដោយសីលធម៌នៃការអនុវត្តក្នុងវិស័យទេសចរណ៍។

ឧទាហរណ៍ អ្នកចូលរួមមួយចំនួនលើកឡើងថាអង្គការមិនមែនរដ្ឋាភិបាលដែលប្រតិបត្តិការក្នុងតំបន់នេះ ជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តក្រមសីលធម៌ និងការពារសិទ្ធិកុមារ[21] ដោយផ្អែកលើលទ្ធផលជាច្រើននៃការស្ទាបស្ទង់មតិនេះ ដែលត្រូវបានពិភាក្សារួចមកហើយ វាមិន មែនជាការអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយ បើទោះជាអ្នកចូលរួមមួយចំនួនអាចមានការយល់ដឹងនៅមានកម្រិតពីឥទ្ធិពលនៃវិស័យទេសចរណ៍ទៅលើកុមារមុនពេលទៅទស្សនាតំបន់នេះ ក៏អ្នកចូលរួមជាច្រើន( ៨៤,៨% ) រាយការណ៍ថាចង់ដឹងព័ត៌មានបន្ថែមអំពីបញ្ហានេះមុនពេលពួកគេធ្វើដំណើរនាពេលអនាគត។ ជាការពិតណាស់ការលើកឡើងរបស់អ្នកចូលរួមមួយចំនួន ពិតជាបង្ហាញថា ប្រហែលជាអាចមានចំណុចខ្វះខាតក្នុងការយល់ដឹងរបស់ពួកគេអំពីបញ្ហាក្រមសីលធម៌ក្នុងវិស័យទេសចរណ៍នៅពេលវាទាក់ទងនឹងកុមារ ( ដូចជាអ្នកចូលរួមជាច្រើនបានទៅទស្សនាមណ្ឌលកុមារកំព្រា )។

---

21 អង្គការដែលត្រូវបានលើកឡើងជាពិសេសរួមមាន៖ គម្រោងគំនូរកុមារកម្ពុជា មិត្តសំឡាញ់ ហ្វ្រែន សុវត្ថិភាពកុមារ អង្គការទស្សនៈពិភពលោក បងប្អូនចាប់ដៃ Hagar ។

ដូចគ្នានេះដែរ ការយល់ឃើញរបស់ភ្ញៀវទេសចរចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ហាក់ដូចជានៅមានកម្រិតជាទិដ្ឋភាពរួមនៃបុរស ស្បែកស ជនដែលមកពីលោកខាងលិចចំណាស់ដើរតួជាព្រានប្រមាញ់។ ប្រការនេះពិតជាធ្វើឲ្យភ្ញៀវទេសចរមើលមិនឃើញពីអ្នកដំណើរមិនមែនជនដែលមកពីលោកខាងលិចដែលចូលរួមក្នុងឥរិយាបថកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងចំណុចដែលថាស្ត្រីក៏អាចចូលរួមក្នុងសកម្មភាពបែបនេះបានដែរ។ វារឹតតែមានការមើលស្រាលទៅទៀតនោះ គឺមានការយល់ឃើញថារឿងទាំងនេះកើតឡើងតែក្នុងករណីមានការជិះជាន់ខ្លាំង ឬបើតាមពាក្យសម្តីរបស់អ្នកចូលរួមម្នាក់ គឺ ផ្នែកមួយនៃវិស័យទេសចរណ៍ដែល "គួរឲ្យស្អប់ខ្ពើម" ប៉ុណ្ណោះ។

ទោះជាយ៉ាងណា ទស្សនៈរបស់ក្រុមអ្នកចូលរួមហាក់បង្ហាញពីកម្រិតសមស្របនៃការយល់ដឹងអំពីការទទួលខុសត្រូវ និងការសម្រេចចិត្តប្រកបដោយសីលធម៌នៃការអនុវត្តក្នុងវិស័យទេសចរណ៍។ ឧទាហរណ៍ អ្នកចូលរួមមួយចំនួនលើកឡើងថាអង្គការមិនមែនរដ្ឋាភិបាលដែលប្រតិបត្តិការក្នុងតំបន់នេះ ជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តក្រមសីលធម៌ និងការពារសិទ្ធិកុមារ

រូបភាពទី៧ ៖ ចម្លើយចំពោះសំណួរ "តើអ្នកចង់ទទួលបានព័ត៌មានប្រភេទណា មុនពេលអ្នកធ្វើដំណើរ ?"




ឧទាហរណ៍ អ្នកចូលរួមម្នាក់លើកឡើងថាគាត់ "ទៅហូបតែនៅភោជនីយដ្ឋានដែលមានគោលនយោបាយការពារ/សង្គ្រោះកុមារ (និង) ស្នាក់នៅតែតាមសណ្ឋាគារដែលរក្សាសុវត្ថិភាពកុមារ"។ ស្ត្រីម្នាក់ទៀតបានសង្កេតឃើញថានាងបានទិញ "ទំនិញខ្លះក្នុងតម្លៃថ្លៃជាងកន្លែងផ្សេងពីហាងដែលគាំទ្រប្រជាជនក្នុងស្រុក និងផ្តល់ការងារដល់ម្តាយឪពុក និងការសិក្សាមានសុវត្ថិភាពដល់កុមារ"។

ចំណុចគោលដែលអ្នកឆ្លើយតបប្រើដើម្បីសម្រេចចិត្តថាទិញទំនិញអ្វីមួយពីអាជីវកម្មដែលមានគោលនយោបាយការពារកុមារ គឺអាស្រ័យលើថាតើមានភស្តុតាងថាមានការអនុវត្តជាក់ស្តែងឬយ៉ាងណា។ ជាចុងក្រោយ វាហាក់ដូចជាថាអ្នកចូលរួមភាគច្រើនចាប់អារម្មណ៍ចំពោះគំនិតផ្តួចផ្តើមបែបនេះ ហើយនឹងគាំទ្រអាជីវកម្មបែបនេះ ប៉ុន្តែពួកគេចង់ដឹងថាតើអាជីវកម្មទាំងនេះត្រូវបានធ្វើសវនកម្ម/វាយតម្លៃយ៉ាងហ្មត់ចត់ដោយភ្នាក់ងារឯករាជ្យដែរឬយ៉ាងណា។
បើទោះជាលទ្ធផលមួយចំនួននៃការស្ទាបស្ទង់មតិនេះនៅមានកម្រិត ក៏ចំណុចនេះបង្ហាញនូវចំណុចគន្លឹះមួយចំនួនទាក់ទងនឹងការរៀបចំយុទ្ធសាស្ត្រលើសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។ ភ្ញៀវទេសចរជាច្រើន (ទោះមិនមែនទាំងអស់) កាន់តែមានភាពឈ្លាសវៃចំពោះការអនុវត្តពេលធ្វើដំណើររបស់ពួកគេ ហើយពួកគេមានឆន្ទៈចំណាយប្រាក់បន្ថែមសម្រាប់ទំនិញ/សេវាកម្ម ដែលមានលក្ខណៈពិសេស គួរឲ្យជឿទុកចិត្តបាន និងបង្ហាញថាផ្តល់ផលប្រយោជន៍ដល់សហគមន៍ម្ចាស់ស្រុក។ ទោះជាយ៉ាងណាក៏ដោយ សូម្បីតែភ្ញៀវទេសចរដែលបើកចំហចំពោះរឿងបែបនេះជួបការលំបាកក្នុងការទទួលព័ត៌មានឲ្យបានគ្រប់គ្រាន់អំពីទំនិញ/សេវាកម្មបែបនេះ ពោលគឺដើម្បីកំណត់ថាតើអ្វីទាំងអស់ពិតជាផ្តល់ផលប្រយោជន៍ប្រាកដមែន។ ពួកគេក៏មានមន្ទិលអំពីការអះអាងដែលគ្មានភស្តុតាងថាផ្តល់ផលប្រយោជន៍ ហេតុនេះពួកគេមិនត្រឹមតែចង់ដឹងពីព័ត៌មាននៃទំនិញក្នុងជម្រើសផ្សេងទៀត តែក៏ចង់ដឹងផងដែរពីភស្តុតាងថាពួកគេពិតជាធ្វើតាមនូវអ្វីដែលបានសន្យា។

# សេចក្តីសន្និដ្ឋានបញ្ចប់

ការស្ទាបស្ទង់មតិនេះត្រូវបានធ្វើឡើងលើអ្នកដំណើរប្រហែលជាង ៣០០នាក់ជុំវិញពិភពលោកក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីស្វែងយល់បន្ថែមពីអ្នកដំណើរដែលមកកាន់ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ប្រភេទនៃការធ្វើដំណើររបស់ពួកគេ ឥរិយាបថ អន្តរសកម្មភាព និងចំណេះដឹងអំពីបញ្ហាដែលប្រឈមដោយកុមារក្នុងស្រុកនៅតាមកន្លែងគោលដៅទេសចរណ៍។ ការស្ទាបស្ទង់មតិនេះផ្តល់នូវព័ត៌មានមួយចំនួនពិសេសទាក់ទងនឹងប្រធានបទឥរិយាបថ អន្តរសកម្មភាព និងចំណេះដឹងរបស់ភ្ញៀវទេសចរអំពីបញ្ហាដែលប្រឈមដោយកុមារម្ចាស់ស្រុកនៅតាមកន្លែងគោលដៅទេសចរណ៍ ប៉ុន្តែការស្ទាបស្ទង់មតិនេះនៅមានកម្រិតក្នុងការតំណាងឲ្យស្ថានភាពប្រជាសាស្ត្រនៃអ្នកដំណើរមកកាន់តំបន់នេះ។[22]
ទោះជាយ៉ាងណាក៏ដោយ ក៏លទ្ធផលនៃការស្ទាបស្ទង់មតិនេះពិតជាផ្តល់នូវចំណុចចាប់ផ្តើមដ៏ល្អសម្រាប់ការបង្កើតយុទ្ធសាស្ត្រទាក់ទងនឹងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។
អ្វីដែលសំខាន់បំផុត លទ្ធផលទាំងនេះបង្ហាញថា អ្នកដំណើរ (គ្រប់អាយុ ភេទ និងសញ្ជាតិ) ជារឿយៗមានអន្តរសកម្មភាពជាមួយកុមារនៅក្នុងតំបន់នេះ។

ទោះជាយ៉ាងណាក្តី ជារឿយៗមានការឲ្យតម្លៃដល់អន្តរសកម្មភាពជាមួយកុមារ ដូចជាការនិយាយជាមួយកុមារ ការបង្រៀនភាសាអង់គ្លេសឲ្យពួកគេ ស្តាប់ពួកគេនិយាយពីជីវិតរបស់ប្រជាជនក្នុងស្រុក និងការលេងកំសាន្តជាមួយពួកគេ ក៏អ្នកដំណើរដែល ត្រូវបានស្ទាបស្ទង់មតិនៅក្នុងការសិក្សានេះហាក់ដូចជាមានអនុស្សាវរីយ៍មិនល្អចំពោះកុមារសុំទាន កុមារលក់អីវ៉ាន់ឲ្យពួកគេ ឬនៅក្នុងរបៀបផ្សេងទៀតដែលកុមារទាំងនោះគឺជាជនរងគ្រោះនៃការកេងប្រវ័ញ្ច។

22 ដូចដែលបានកំណត់រួចហើយថាពិតជាមានភាពលម្អៀងនៅក្នុងសំណាកគំរូនេះទាក់ទងនឹងអាយុ ភេទ សញ្ជាតិ និងប្រហែលជាអាចកាន់តែសំខាន់ទៅទៀត គឺប្រភេទអ្នកដំណើរ។

អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិនៃការសិក្សានេះ រាយការណ៍ថាមានការឆ្លើយតបខាងផ្លូវចិត្តយ៉ាងអវិជ្ជមាន (ក្រៀមក្រំ បន្ទោសខ្លួនឯង ខឹង អន្ទះសារ ស្អប់ខ្ពើម) នៅពេលឃើញកុមាររស់នៅក្នុងស្ថានភាពខ្សត់ខ្សោយ ត្រូវបានបង្ខំឲ្យធ្វើការនៅតាមចិញ្ចើមថ្នល់ (ដោយជារឿយៗ គ្មានការថែរក្សាពីមនុស្សពេញវ័យ) មិនបានទទួលការអប់រំ ហើយកាន់តែធ្ងន់ធ្ងរ គឺត្រូវបានរំលោភបំពានក្នុងរបៀបណាមួយ។ មន្ត្រីឧស្សាហកម្មទេសចរណ៍ និងប្រតិបត្តិករវិស័យទេសចរណ៍ចាំបាច់ត្រូវយកចិត្តទុកដាក់អំពីបញ្ហាទាំងនេះ ដែលប៉ះពាល់ដល់អារម្មណ៍របស់ភ្ញៀវទេសចរ ហើយដែលភ្ញៀវទេសចរនឹងយកទៅពិភាក្សាជាមួយមិត្តភក្តិ និងគ្រួសាររបស់ពួកគេនៅពេលទៅដល់ប្រទេសដើមរបស់ពួកគេវិញ។ហេតុនេះ បញ្ហានេះអាចប៉ះពាល់ជាខ្លាំងដល់កេរ្តិ៍ឈ្មោះរបស់គោលដៅទេសចរណ៍។

ទោះជាយ៉ាងនេះក្តី បើទោះជាមានការឆ្លើយតបផ្នែកផ្លូវចិត្តយ៉ាងអវិជ្ជមានចំពោះការជួបប្រទះកុមារដែលរងការរំលោភបំពាន/កេងប្រវ័ញ្ច ហើយការជួបប្រទះទាំងនេះ ពេលខ្លះអាចធ្វើឲ្យភ្ញៀវទេសចរកាត់បន្ថយរយៈពេលនៃដំណើរកំសាន្តរបស់ពួកគេ ឬស្ទាក់ស្ទើរមិនចង់ត្រឡប់មកកាន់គោលដៅទេសចរណ៍នេះម្តងទៀត ក៏ត្រឹមតែអ្នកដំណើរមួយចំនួនតូចប៉ុណ្ណោះដែលធ្វើសកម្មភាពដោយផ្ទាល់ ដើម្បីឆ្លើយតបចំពោះករណីសង្ស័យថាមានការកេងប្រវ័ញ្ច ឬរំលោភបំពាន។ ពួកគេភាគច្រើនពិភាក្សាអំពីរឿងនេះជាមួយមិត្តភក្តិ ប៉ុន្តែមួយចំនួនតូចប៉ុណ្ណោះដែលមានអារម្មណ៍ស្រួលក្នុងការរាយការណ៍អំពីរឿងនេះដល់អាជ្ញាធរ ឬសូម្បីតែទៅឲ្យបុគ្គលិកក្នុងវិស័យទេសចរណ៍។ ដោយហេតុថាអ្នកដំណើរដែលចូលរួមនៅក្នុងការស្ទាបស្ទង់មតិនេះហាក់ដូចជាមានការយល់ដឹងគ្រប់គ្រាន់ (យ៉ាងហោចបានទូលំទូលាយ) អំពីបញ្ហាដែលកុមារម្ចាស់ស្រុកជួបប្រទះ នោះកង្វះការរាយការណ៍នេះអាចបណ្តាលមកពីកត្តាសំខាន់ៗចំនួនបី ៖

១. កង្វះព័ត៌មានលម្អិតស្តីពីទំនាក់ទំនងរវាងការកេងប្រវ័ញ្ចកុមារ និងវិស័យទេសចរណ៍។
២. ភាពមន្ទិល/ស្ទាក់ស្ទើរអំពីកិច្ចការដែលពួកគេក្នុងនាមជាភ្ញៀវទេសចរអាចធ្វើបាន។
៣. ភាពមន្ទិលថាតើការរាយការណ៍អំពីកង្វល់របស់ពួកគេនាំមកនូវការផ្លាស់ប្តូរដែរឬយ៉ាងណា។
៤. ភាពមន្ទិលអំពីរឿងដែលកំពុងកើតឡើង។

បើទោះជាកត្តាចុងក្រោយនេះប្រហែលជាពិបាកក្នុងការដោះស្រាយ (ជាពិសេសនៅពេលគេពិចារណាអំពីភាសា) ក៏កត្តាទីមួយ ទីពីរ និងទីបីមិនសូវជាពិបាកដោះស្រាយនោះទេ។
ជាការច្បាស់ណាស់ ភាគច្រើននៃអ្នកឆ្លើយតបចំពោះការស្ទាបស្ទង់មតិនេះ បានប្រមូលព័ត៌មានបានយ៉ាងហោចណាស់មួយចំនួនស្តីពីកុមារងាយរងគ្រោះដោយការកេងប្រវ័ញ្ច និងរំលោភបំពានក្នុងគោលដៅទេសចរណ៍។
[23] ជាការពិតណាស់ អ្នកដំណើរជាច្រើនបានដឹងពីបញ្ហាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ ហើយភាគច្រើនដឹងថាការជួយទិញអីវ៉ាន់ពីកុមារលក់ដូរ ឬឲ្យលុយ ដល់កុមារសុំទានជាដើមគឺអាចបង្កជាបញ្ហា។ ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ បើទោះជាបានបំពេញការស្ទាបស្ទង់មតិស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ក៏អ្នកឆ្លើយតបនៅតែមានទំនោរសង្កត់ធ្ងន់ពីផលប៉ះពាល់ខាងបរិស្ថាននៃវិស័យទេសចរណ៍ជាជាងផលប៉ះពាល់ផ្នែកសង្គមវប្បធម៌ ដោយ ៤៤% លើកឡើងថា

23 ជាទូទៅ ចំណុចនេះហាក់ដូចជាមកពីអង្គការមិនមែនរដ្ឋាភិបាល និងសេចក្តីប្រកាស/ផ្លាកសញ្ញា/ខិតប័ណ្ណនៅតាមកន្លែងគោលដៅទេសចរណ៍។ ប្រភពផ្សេងទៀតនៃព័ត៌មាននេះរួមមានមគ្គុទ្ទេសក៍ទេសចរ និងអ្នកមានអាជីពក្នុងវិស័យទេសចរណ៍ ប្រភពតាមអ៊ីនធឺណេត និងប្រព័ន្ធផ្សព្វផ្សាយទូទៅ (ដូចជាសៀវភៅ របាយការណ៍ព័ត៌មាន កម្រងឯកសារ)។ ជួនកាលអ្នកដំណើររាយការណ៍ថាបានធ្វើការស្រាវជ្រាវបន្ថែមទៀតអំពីបញ្ហានេះ ហើយអ្នកដំណើរមួយចំនួនក៏បានលើកឡើងថាបានស្វែងយល់ពីបញ្ហានៃការកេងប្រវ័ញ្ចលើកុមារ និងរបៀបដោះស្រាយតាមរយៈអ្នកដំណើរដទៃទៀត មិត្តភក្តិ និងសមាជិកគ្រួសារ។

ផលប៉ះពាល់ទៅលើបរិស្ថានក្នុងស្រុកគឺភាគច្រើនអវិជ្ជមាន ហើយត្រឹមតែ ៣២,៥% លើកឡើងថា ផលប៉ះពាល់នៃវិស័យទេសចរណ៍ទៅលើកុមារ និងមនុស្សវ័យក្មេងគឺភាគច្រើនអវិជ្ជមាន។ ក្រៅពីការស្ទាក់ស្ទើរនេះ (ដែលជាញឹយៗផ្តោតលើគំនិតដែលថាវិស័យទេសចរណ៍នាំមកនូវកំណើន សេដ្ឋកិច្ចដល់កុមារទាំងនេះ និងគ្រួសាររបស់ពួកគេ) អ្នកចូលរួមជាច្រើនក្នុងការស្ទាបស្ទង់មតិនេះក៏ហាក់ ដូចជាមិនសូវយល់ដឹង ឬមានកង្វល់ពីឥរិយាបថកេងប្រវ័ញ្ចដូចជាការឲ្យអាហារ និងអំណោយដល់កុមារ ការថតរូបកុមារ ឬទៅទស្សនាមណ្ឌលកុមារកំព្រា (តាមពិតទៅ ជួនកាលឥរិយាបថទាំងនេះត្រូវបានផ្តល់ជា យុទ្ធសាស្ត្រដើម្បីដោះស្រាយជាមួយកុមារលក់ដូរ ឬសុំទានផងក៏មាន)។

ដូច្នេះ រាល់យុទ្ធនាការទាក់ទងនឹងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ចាំបាច់ត្រូវធានាថាព័ត៌មាន លម្អិតត្រូវផ្តល់ឲ្យភ្ញៀវទេសចរដែលអាចមកកាន់តំបន់នេះស្តីពីរាល់ឥរិយាបថដែលអាចប៉ះពាល់ដល់ កុមារ គឺមិនគ្រាន់តែឥរិយាបថដែលបានបោះពុម្ពផ្សាយជាច្រើនរួចមកហើយ និង/ឬដែលគួរឲ្យរន្ធត់/ ស្មុគស្មាញខ្លាំងនោះទេ។ តាមរយៈការស្ទាបស្ទង់មតិនេះ ហាក់ដូចជាភ្ញៀវទេសចរមានទំនោរចាត់ទុកការ កេងប្រវ័ញ្ចផ្លូវភេទលើកុមារស្មើនឹងការរំលោភបំពានលើកុមារ ហេតុនេះតាមរយៈការមិនចូលរួមក្នុងការ កេងប្រវ័ញ្ចផ្លូវភេទលើកុមារ នោះពួកគេគិតថាពួកគេបានធ្វើដំណើរប្រកបដោយការទទួលខុសត្រូវហើយ។ ដូចគ្នានេះដែរ អ្នកចូលរួមជាច្រើនសន្មត់ថាជនល្មើសដែលកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅក្នុងវិស័យ ទេសចរណ៍ គឺមានតែបុរសស្បែកស ជនដែលមកពីលោកខាងលិច ដែលជាថ្មីម្តងទៀត ស្ថានភាពពិតគឺ មានលក្ខណៈស្មុគស្មាញជាងនេះ។

ភ្ញៀវទេសចរក៏ត្រូវការព័ត៌មានស្តីពីកិច្ចការពិតប្រាកដដែលពួកគេអាចធ្វើដើម្បីជួយ។ ភ្ញៀវទេសចរភាគច្រើន ដែលត្រូវបានស្ទាបស្ទង់មតិ យល់ថាដើម្បីមានលទ្ធភាពកាន់តែប្រសើរក្នុងការជួយរក្សាសុវត្ថិភាពកុមារ និងមនុស្សវ័យក្មេង នោះអ្នកដំណើរចាំបាច់ត្រូវការការអប់រំបន្ថែម ដើម្បីដឹងថានរណាដែលពួកគេអាចទៅរក ឲ្យជួយ តើបែបបទ និងនីតិវិធីរាយការណ៍ពីការរំលោភបំពាន/កេងប្រវ័ញ្ចក្នុងតំបន់នេះត្រូវធ្វើឡើងយ៉ាងដូច ម្តេច និងឱកាសដើម្បីបង្ហាញឲ្យច្បាស់នូវអំណាចក្នុងការចំណាយរបស់ពួកគេប្រកបដោយប្រសិទ្ធភាព។

អ្នកចូលរួមជាច្រើនគាំទ្រគំនិតនៃគោលនយោបាយសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងចង់ដឹងពី របៀបចំណាយប្រាក់របស់ពួកគេដើម្បីជួយឲ្យបានកាន់តែច្រើនដល់កុមារ/មនុស្សវ័យក្មេង/សហគមន៍ ក្នុងស្រុក ប៉ុន្តែជួនកាលវាជាការពិបាកដើម្បីទទួលបានព័ត៌មានទាំងនេះ។ ត្រង់ចំណុចនេះ អ្នកចូលរួមមួយ ចំនួនបង្ហាញពីបំណងចង់បានគោលការណ៍ណែនាំ/យុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីជួយពួកគេឲ្យដោះ ស្រាយបញ្ហាទាំងនេះនៅពេលធ្វើដំណើរ ហើយបាននិយាយថាពួកគេមានឆន្ទៈក្នុងការចំណាយប្រាក់បន្ថែម ខ្លះលើទំនិញ/សេវាកម្មដែលផលិត និងផ្តល់ជូនក្នុងបរិយាកាសដែលរក្សាសុវត្ថិភាពកុមារ។ ចំណុចនេះ ស្របនឹងបំណងប្រាថ្នាដ៏មុតមាំក្នុងការជួយ ដែលលើកឡើងដោយអ្នកចូលរួម។ ការឆ្លើយតបដ៏គួរឲ្យចាប់ អារម្មណ៍មួយចំពោះសំណួរអំពីកន្លែងដែលអ្នកចូលរួមចង់ទទួលបានព័ត៌មានអំពីការធ្វើដំណើរប្រកបដោយ ការទទួលខុសត្រូវ និង/ឬវប្បធម៌ក្នុងស្រុក/សហគមន៍ក្នុងស្រុកមានដូចតទៅ៖

> ខ្ញុំគិតថាវាមានសារៈសំខាន់ណាស់ក្នុងការបណ្តុះទស្សនៈជារួមបន្តិចម្តងៗដល់វិស័យធ្វើ ដំណើរដែលអាចជូនព័ត៌មានដល់ការសម្រេចចិត្តជាលក្ខណៈបុគ្គល។ ការជួយមនុស្ស ឲ្យទទួលបានព័ត៌មានដើម្បីអាចសម្រេចចិត្តបានត្រឹមត្រូវ ជាជាងផ្តល់នូវបញ្ជីដំបូន្មាន ឲ្យធ្វើតាមនៃ "ជម្រើសក្រមសីលធម៌" (មានសារៈសំខាន់)។ បើទោះ (បញ្ជីនេះ) អាចជួយបានខ្លះដែរ វាក៏អាចធ្វើឲ្យមនុស្សមើលរំលងជម្រើសផ្សេងទៀត។ (វា)ដូចជា

ឥទ្ធិពលនៃពិភពឯកោដែលមនុស្សមើលរំលងជម្រើសល្អៗ ហើយព្យាយាមទៅរកកន្លែងមួយដែលសរសេរនៅក្នុង "សៀវភៅ"។ ភាពពិតផ្លាស់ប្តូរយ៉ាងលឿនដែលគេមិនអាចមានពេលទៅកែវាទាន់ឡើយ។ (បុរស ជនជាតិកម្ពុជា អាយុ៣០ឆ្នាំ)

ជាការពិត គោលការណ៍ណែនាំមានប្រយោជន៍សម្រាប់ភ្ញៀវទេសចរ ហើយភ្ញៀវទេសចរជាច្រើនដែលត្រូវបានស្ទាបស្ទង់មតិនៅក្នុងការសិក្សានេះ យល់ថាគោលការណ៍ណែនាំនឹងផ្តល់នូវផលប្រយោជន៍។ ក៏ប៉ុន្តែដូចដែលអ្នកចូលរួមនេះបានបង្ហាញថា វាហាក់ដូចជាការអប់រំភ្ញៀវទេសចរ និងការផ្តល់អំណាចពួកគេក្នុងការទទួលខុសត្រូវសម្រាប់ការសម្រេចចិត្តរបស់ពួកគេ និងធ្វើសកម្មភាពប្រកបដោយសីលធម៌ គឺងាយនឹងនាំមកនូវឥទ្ធិពលយូរអង្វែងទាក់ទងនឹងសុវត្ថិភាពកុមារ និងការធ្វើដំណើរប្រកបដោយការទទួលខុសត្រូវ។ ជាការពិត ភ្ញៀវទេសចរខ្លះងាយនឹងបើកចំហចំពោះការអប់រំនេះជាងអ្នកដទៃ (ហើយអ្នកដែលចូលរួមក្នុងការស្ទាបស្ទង់មតិនេះអាចនឹងបើកចំហចំពោះគំនិតនេះជាងអ្នកដទៃ) ហេតុនេះរាល់យុទ្ធសាស្រ្ត ០៥ ត្រូវរៀបចំឲ្យមានច្រើនសណ្ឋាន ៖ កាន់តែលម្អិតសម្រាប់អ្នកដែលចង់បានវា ហើយមិនសូវលម្អិតសម្រាប់អ្នកដែលមិនសូវចង់បានវា។

ត្រង់ចំណុចនេះ វាក៏មានលក្ខណៈច្បាស់លាស់ផងដែរថារាល់យុទ្ធនាការដែលចង់បង្កើនការយល់ដឹងអំពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ចាំបាច់ត្រូវប្រតិបត្តិការក្នុងប្រទេសគោលដៅ ទេសចរណ៍ក៏ដូចជាប្រទេសដើមរបស់ភ្ញៀវទេសចរ។
ហេតុនេះ គេត្រូវប្រើប្រាស់បណ្តាញដ៏ធំរបស់មន្រ្តីឧស្សាហកម្មទេសចរណ៍ អាជីវកម្មទេសចរណ៍ និងប្រព័ន្ធផ្សព្វផ្សាយទាក់ទងនឹងវិស័យទេសចរណ៍ ដើម្បីផ្សព្វផ្សាយព័ត៌មាន និងបង្កើនការយល់ដឹងពីយុទ្ធនាការអំពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ដែលត្រូវបានបង្កើតឡើង។
អ្នកចូលរួមមួយចំនួនក្នុងការស្ទាបស្ទង់មតិនេះ បង្ហាញថាវាយឺតពេលទៅហើយក្នុងការទទួលបានការយល់ដឹងពីបញ្ហានៃការកេងប្រវ័ញ្ចលើកុមារនៅក្នុងប្រទេសនេះ (ពោលគឺពួកគេបានចូលរួមក្នុងឥរិយាបថដែលអាចបង្កបញ្ហារួចទៅហើយ)។ ដោយសារភាពចម្រុះគ្នានៃប្រភេទអ្នកដំណើរ (ហើយការសិក្សានេះមិនបានបញ្ចូលគ្រប់ប្រភេទនៃអ្នកដំណើរ) និងប្រភពផ្សេងៗគ្នានៃព័ត៌មានដែលភ្ញៀវទេសចរប្រើនោះ ព័ត៌មានអំពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ចាំបាច់ត្រូវបានផ្តល់ជូនតាមប្រព័ន្ធផ្សព្វផ្សាយតាម អ៊ីនធឺណេតនិង មិនតាមអ៊ីនធឺណេតជាច្រើនប្រភេទ ដូចជាប្រព័ន្ធផ្សព្វផ្សាយសង្គម គេហទំព័រ សេចក្តីប្រកាស ខិតប័ណ្ណ សៀវភៅមគ្គុទ្ទេសក៍ ផ្លាកសញ្ញា និងកូនខិតប័ណ្ណ (អ្នកចូលរួមខ្លះក៏ស្នើឲ្យភ្ជាប់ខិតប័ណ្ណតូចៗជាមួយនឹងទិដ្ឋាការតែម្តង)។

សរុបមក វាមានលក្ខណៈច្បាស់តាមរយៈការស្ទាបស្ទង់មតិនេះដែលភ្ញៀវទេសចរជាច្រើនមានភាពឈ្លាសវៃក្នុងការធ្វើដំណើរក្នុងរបៀបវិជ្ជមាន និងពិតជាមានបំណងចង់ជួយកាត់បន្ថយភាពក្រីក្រ និងបញ្ហា សង្គមដទៃទៀត (ដូចជា ខ្វះការសិក្សា ទីជម្រក និងការងារ) នៅតាមប្រទេសដែលពួកគេទៅទស្សនា។
ភាគច្រើននៃភ្ញៀវទេសចរដែលត្រូវបានស្ទាបស្ទង់មតិនេះ បានទទួលឥទ្ធិពលគួរឲ្យកត់សម្គាល់ពីការជួបប្រទះនឹងកុមារនៅក្នុងតំបន់នេះ និងជាពិសេសដោយអ្វីដែលពួកគេយល់ថាជាស្ថានភាពដែលទាក់ទងនឹងការកេងប្រវ័ញ្ច និងរំលោភបំពាន។

ក៏ប៉ុន្តែការយល់ដឹងរបស់ភ្ញៀវទេសចរអំពីរបៀបឆ្លើយតបឲ្យល្អបំផុតចំពោះស្ថានភាពនេះគឺនៅមានកម្រិតហើយ

អ្នកចូលរួមភាគច្រើនបង្ហាញភាពមន្ទិលអំពីរបៀបនៃការកេងប្រវ័ញ្ច និងរំលោភបំពានលើកុមារត្រូវបានដោះស្រាយដោយសហគមន៍ក្នុងស្រុក។ ការដោះស្រាយចំពោះភាពមន្ទិលបែបនេះ ក៏ដូចជាកេរ្តិ៍ឈ្មោះអវិជ្ជមាននៃសហគមន៍ក្នុងស្រុក និងអាជ្ញាធរមូលដ្ឋានដែលទាក់ទងនឹងភាពមន្ទិលទាំងនេះ គប្បីត្រូវបានចាត់ទុកថាជាអាទិភាពគន្លឹះមិនមែនសម្រាប់តែអ្នកដែលចូលរួមក្នុងគម្រោងកុមារភាពប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ប្រតិបត្តិករក្នុងវិស័យទេសចរណ៍ សមាជិកនៃសហគមន៍ទេសចរណ៍សកល និងសម្រាប់អាជ្ញាធរមូលដ្ឋាន និងរដ្ឋាភិបាលនៅក្នុងប្រទេសជាគោលដៅទេសចរណ៍ផងដែរ។ លើសពីនេះទៅទៀត យុទ្ធសាស្ត្រសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍អាចជាមធ្យោបាយមួយដែលរដ្ឋាភិបាល និងឧស្សាហកម្មទេសចរណ៍អាចរួមចំណែកដើម្បីបង្កើតកេរ្តិ៍ឈ្មោះ និងវប្បធម៌វិជ្ជមានសម្រាប់គោលដៅទេសចរណ៍ ហើយដែលឈានទៅរកឧស្សាហកម្មទេសចរណ៍ដែលកាន់តែមានលក្ខណៈ វប្បធម៌សង្គម និងសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

# អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ថែមទៀត

ដើម្បីពង្រឹងបន្ថែមលើការចាប់ផ្តើមពិនិត្យពីទស្សនៈរបស់ភ្ញៀវទេសចរនេះ គេគប្បីធ្វើការស្រាវជ្រាវបន្ថែមទៀតដើម្បីរួមបញ្ចូលនូវសំណាកគំរូដែលកាន់តែធំ និងចម្រុះ ដូចជាការយល់ឃើញរបស់អ្នកដែលចូលរួមក្នុងវិស័យទេសចរណ៍តាមរមណីយដ្ឋាន ឬដំណើរកំសាន្តជាក្រុមទៅកាន់តំបន់នេះ (ឬហៅម្យ៉ាងទៀតថា "ភ្ញៀវទេសចរដើរកំសាន្តជាក្រុមធំ") អ្នកដំណើរដែលមានអាយុច្រើន ការយល់ឃើញរបស់បុរស (ឬយ៉ាងហោចណាស់ត្រូវមានការចូលរួមពីបុរសច្រើនជាងនេះ) និងអ្នកដែលមិននិយាយភាសាអង់គ្លេស។ វិធីសាស្ត្រផ្សេងទៀតដូចជាការពិភាក្សាជាក្រុម ឬបទសម្ភាសន៍ (ដែលជារឿយៗអាចឲ្យគេទទួលព័ត៌មានលម្អិតជាងការស្ទាបស្ទង់មតិ) ក៏អាចត្រូវបានប្រើជាមួយភ្ញៀវទេសចរក្នុងពេលពួកគេកំពុងស្នាក់នៅក្នុងគោលដៅទេសចរណ៍ជាជាងពេលពួកគេត្រឡប់មកប្រទេសដើមរួចហើយនោះ។ ប្រការនេះអាចជួយបញ្ចៀសបាននូវបញ្ហាទាក់ទងនឹងការព្យាយាមនឹកចាំ និងក៏អាចជួយដល់នឹកឃើញរូបភាពកាន់តែច្បាស់ និងភ្លាមៗនៃព្រឹត្តិការណ៍ដែលកំពុងកើតឡើង។ ក្រៅពីនេះ ការសង្កេតឥរិយាបថរបស់ភ្ញៀវទេសចរក៏មានសារៈសំខាន់ផងដែរ ដើម្បីបំពេញបន្ថែមដល់វិធីសាស្ត្រស្រាវជ្រាវដែលស្វែងយល់បានតែឥរិយាបថដែលត្រូវបានរាយការណ៍ប្រាប់។

"ខ្ញុំគិតថា វាមានសារៈសំខាន់ណាស់ក្នុងការបណ្តុះទស្សនៈជារួម បន្តិចម្តងៗដល់វិស័យធ្វើដំណើរ ដែលអាចជូនព័ត៌មានដល់ការសម្រេចចិត្តជាលក្ខណៈបុគ្គល។ ការជួយមនុស្សឲ្យទទួលបានព័ត៌មានដើម្បីអាចសម្រេចចិត្តបានត្រឹមត្រូវជាជាងប្រគល់ឲ្យនូវបញ្ជីដំបូន្មានឲ្យធ្វើតាមនៃ "ជម្រើសសីលធម៌" (មានសារៈសំខាន់ណាស់ )។"


SONY
Cyber-shot

# ឧបសម្ព័ន្ធ ៖ កម្រងសំណួរ

១. តើអ្នកធ្លាប់ធ្វើដំណើរទៅប្រទេសកម្ពុជា ឡាវ ថៃ ឬវៀតណាម ("តំបន់នេះ") ក្នុងរវាង៥ឆ្នាំចុងក្រោយនេះ (រួមបញ្ចូលទាំងការស្នាក់នៅរយៈពេលយូរ) ដែរឬទេ?

{ } បាទ/ចាស  { } ទេ

២. តើប្រទេសណាដែលអ្នកបានធ្វើដំណើរទៅក្នុងរវាង៥ឆ្នាំចុងក្រោយនេះ? (ចូរគូសយកគ្រប់ចម្លើយដែលត្រឹមត្រូវ)

{ } កម្ពុជា  { } ឡាវ

{ } ថៃ  { } វៀតណាម

៣. តើអ្វីជាមូលហេតុចម្បងនៃការធ្វើដំណើររបស់អ្នក?

{ } អាជីវកម្ម

{ } វិស្សមកាល

{ } ទៅលេងគ្រួសារ/មិត្តភក្តិ

{ } មូលហេតុសាសនា

{ } ផ្សេងទៀត (សូមបញ្ជាក់)______________

៤. តើភាគច្រើនអ្នកធ្វើដំណើររបៀបណា? (ឧ.ជាអ្នកដំណើរឯករាជ្យ អ្នកដំណើរសាក់កាដូ ជាផ្នែកនៃដំណើរកំសាន្តជាក្រុម ជាផ្នែកនៃដំណើរកំសាន្តជាលក្ខណៈគ្រួសារ -ល-)

________________________________________

______________________________________

៥. តើប្រព័ន្ធផ្សព្វផ្សាយអ្វីខ្លះដែលអ្នកប្រើដើម្បីរៀបផែនការធ្វើដំណើររបស់អ្នកទៅកាន់តំបន់នេះ? (ចូរគូសយកគ្រប់ចម្លើយដែលត្រឹមត្រូវ)

{ } ប្រព័ន្ធផ្សព្វផ្សាយសង្គម (Twitter, Facebook -ល-)

{ } សៀវភៅមគ្គុទ្ទេសក៍ (Lonely Planet, Rough Guides, Time Out -ល- )

{ } គេហទំព័រ និងកម្មវិធីស្តីពីការធ្វើដំណើរ (TripAdvisor -ល-)

{ } ប្លុកស្តីពីការធ្វើដំណើរនៅលើអ៊ីនធឺណេត

{ } ខិតប័ណ្ណផ្សេងទៀត ៖

បើអ្នកស្គាល់ប្លុកស្តីពីការធ្វើដំណើរនៅលើ អ៊ីនធឺណេត ឬប្រភពផ្សេងទៀតដែលជួយអ្នកបានច្រើន សូមសរសេរមួយនៅទីនេះ ៖ ____________________

________________________________________

៦. តើអ្នកស្នាក់នៅក្នុងប្រទេសនីមួយៗរយៈពេលយូរប៉ុណ្ណាដែរ? (សូមជ្រើសរើស គ្មាន ប្រសិនបើអ្នកមិនទៅទស្សនាប្រទេសនេះក្នុងរវាង៥ឆ្នាំចុងក្រោយ) កម្ពុជា ៖

{ } តិចជាង១សប្តាហ៍

{ } ចន្លោះពី១-៤សប្តាហ៍

{ } ចន្លោះពី១-៣ខែ

{ } ចន្លោះពី៣-៦ខែ

{ } លើសពី៦ខែ

ឡាវ ៖

{ } តិចជាង១សប្តាហ៍

{ } ចន្លោះពី១-៤សប្តាហ៍

{ } ចន្លោះពី១-៣ខែ

{ } ចន្លោះពី៣-៦ខែ

{ } លើសពី៦ខែ

ថៃ ៖

{ } តិចជាង១សប្តាហ៍

{ } ចន្លោះពី១-៤សប្តាហ៍

{ } ចន្លោះពី១-៣ខែ

{ } ចន្លោះពី៣-៦ខែ

{ } លើសពី៦ខែ

វៀតណាម ៖

{ } តិចជាង១សប្តាហ៍

{ } ចន្លោះពី១-៤សប្តាហ៍

{ } ចន្លោះពី១-៣ខែ

{ } ចន្លោះពី៣-៦ខែ

{ } លើសពី៦ខែ

៧. តើសកម្មភាពដូចតទៅណាខ្លះដែលអ្នកបានធ្វើនៅពេលអ្នកស្ថិតនៅតំបន់នេះ ? (ចូរគូសយកគ្រប់ចម្លើយដែលត្រឹមត្រូវ)

{ } ទស្សនាមណ្ឌលកុមារកំព្រា

{ } បង្រៀនភាសាអង់គ្លេសដល់មនុស្សពេញវ័យ

{ } ធ្វើការស្ម័គ្រចិត្តតាមគម្រោងបរិស្ថាន

{ } ធ្វើដំណើរទៅសំណង់អាណាធិប្បតេយ្យ និងឬសហគមន៍ងាយរងគ្រោះផ្សេងទៀត

{ } បង្រៀនភាសាអង់គ្លេសដល់កុមារ ឬមនុស្ស វ័យក្មេង

{ } ទិញទំនិញ ឬសេវាកម្មពីអាជីវកម្មដែលផ្តល់ប្រយោជន៍ដល់សហគមន៍ម្ចាស់ស្រុក

{ } ធ្វើការស្ម័គ្រចិត្តតាមអង្គការជួយកុមារ

{ } បរិច្ចាគលុយដល់អង្គការសប្បុរសធម៌ជួយដល់ កុមារ ឬមនុស្សវ័យក្មេង

{ } គ្មានក្នុងជម្រើសខាងលើ

៨. តើមានឃើញកុមារ ឬមនុស្សវ័យក្មេង (អាយុក្រោម ១៨ឆ្នាំ) ធ្វើសកម្មភាពដូចតទៅនៅក្នុងតំបន់នេះដែរឬទេ ? (ចូរគូសយកគ្រប់ចម្លើយដែលត្រឹមត្រូវ)

{ } សម្តែងសិល្បៈតាមចិញ្ចើមផ្លូវ

{ } ធ្វើការតាមភោជនីយដ្ឋាន ឬសណ្ឋាគារ

{ } ដើររើសសំរាម

{ } ធ្វើការក្នុងរបររកស៊ីផ្លូវភេទ

{ } ធ្វើការជាមគ្គុទ្ទេសក៍ទេសចរ

{ } លក់វត្ថុអនុស្សាវរីយ៍

{ } សុំទាន

{ } គ្មានក្នុងជម្រើសខាងលើយោបល់ (តាមជម្រើស) ៖

______________________________

______________________________

៩. នៅពេលស្នាក់នៅក្នុងតំបន់នេះ តើអ្នកមានទិញអីវ៉ាន់ពីអ្នកលក់ជាកុមារ ឬមនុស្សវ័យក្មេងដែរឬទេ ?

{ } បាទ/ចាស { } ទេ

{ } មិនដឹង/មិនចាំ បើសិនអ្នកមិនបានទិញទេ
ចូរពណ៌នាពីមូលហេតុ ៖ ________________

______________________________

១០. នៅពេលស្នាក់នៅក្នុងតំបន់នេះតើអ្នកមានឲ្យលុយទៅកុមារ ឬមនុស្សវ័យក្មេងដើរសុំទានដែរឬទេ ?

{ } បាទ/ចាស { } ទេ

{ } មិនដឹង/មិនចាំ បើសិនអ្នកមិនបានទិញទេ
ចូរពណ៌នាពីមូលហេតុ ៖ ________________

______________________________

១១. តើអ្នកមានអន្តរសកម្មភាពផ្សេងទៀតជាមួយកុមារ និងមនុស្សវ័យក្មេងម្ចាស់ស្រុក នៅពេលស្នាក់នៅតំបន់នេះដែរឬទេ ?

{ } បាទ/ចាស { } ទេ

{ } មិនដឹង/មិនចាំ បើសិនអ្នកមិនមានទេ
ចូរពណ៌នាពីមូលហេតុ ៖ ________________

______________________________

១២. នៅពេលស្នាក់នៅក្នុងតំបន់នេះ តើមានឃើញរឿង អ្វីមួយដែលធ្វើឲ្យគិតថាកុមារ ឬមនុស្សវ័យក្មេង (អាយុក្រោម១៨ឆ្នាំ)អាចជួបប្រទះ ឬមានហានិភ័យនឹងការរំលោភបំពាន/កេងប្រវ័ញ្ចដែរឬទេ ?

{ } បាទ/ចាស { } ទេ

{ } មិនដឹង/មិនចាំ បើសិនអ្នកមិនមានទេ
ចូរពណ៌នាពីមូលហេតុ ៖ ________________

______________________________

១៣. តើអ្នកប្រាប់ពីកង្វល់របស់អ្នកដល់នរណា?

{ } មិនមានទេ

{ } អ្នកដំណើរផ្សេងទៀត

{ } បុគ្គលិកសណ្ឋាគារ

{ } ប៉ូលីសទទួលបន្ទុកខាងភ្ញៀវទេសចរ

{ } ផ្សេងទៀត (សូមបញ្ជាក់)

______________________________

១៤. ហេតុអ្វីបានជាអ្នកមិនប្រាប់អ្នកដទៃពីកង្វល់របស់អ្នក?

{ } រឿងនេះមិនទាក់ទងនឹងខ្ញុំ

{ } ខ្ញុំខ្លាចថាខ្ញុំអាចធ្វើឲ្យស្ថានភាពកាន់តែធ្ងន់ធ្ងរសម្រាប់កុមារ/មនុស្សវ័យក្មេង

{ } ខ្ញុំជឿថាការរាយការណ៍ពីស្ថានភាពនេះនឹងមិនធ្វើឲ្យមានរឿងអ្វីផ្លាស់ប្តូរនោះទេ

{ } ខ្ញុំភ័យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន

{ } ខ្ញុំមិនសូវច្បាស់ថាអាចធ្វើសកម្មភាពបាន

{ } ខ្ញុំមិនដឹងថាត្រូវនិយាយប្រាប់អ្នកណា

{ } ផ្សេងទៀត (សូមបញ្ជាក់)

១៥. តើអ្នកប្រាប់អ្នកដទៃពីកង្វល់របស់អ្នកតាមរបៀបណា?

{ } និយាយផ្ទាល់

{ } អ៊ីមែល

{ } ទូរស័ព្ទ

{ } ប្រព័ន្ធផ្សព្វផ្សាយសង្គម
(Twitter, Facebook -ល-)

{ } ផ្សេងទៀត (សូមបញ្ជាក់)

______________________________

១៦. តើមានការឆ្លើយតបចំពោះការប្រាប់របស់អ្នកដែរឬទេ?

{ } បាទ/ចាស { } ទេ

{ } មិនដឹង/មិនចាំ

បើមិនមានទេ ចូរពណ៌នាពីមូលហេតុ ៖

______________________________

______________________________

១៧. តើអ្នកមានទទួលបានព័ត៌មានស្តីពីរបៀបការពារកុមារ និងមនុស្សវ័យក្មេង (អាយុក្រោម១៨ឆ្នាំ) ពីការរំលោភបំពាន/កេងប្រវ័ញ្ចនៅគោលដៅទេសចរណ៍ដែរឬទេ? (ប្រសិនបើអ្នកមានចម្លើយច្រើនជាងមួយសូមផ្តល់យោបល់)

{ } បាទ/ចាស មុនពេលមកដល់តំបន់នេះ

{ } បាទ/ចាស ក្នុងពេលស្នាក់នៅតំបន់នេះ

{ } បាទ/ចាស បន្ទាប់ពីចាកចេញពីតំបន់នេះ

{ } ទេ

{ } មិនដឹង/មិនចាំ

បើអ្នកទទួលបានព័ត៌មាននេះសូមពណ៌នាពីប្រព័ន្ធផ្សព្វផ្សាយ ប្រភព និងខ្លឹមសារនៅទីនេះ៖

______________________________

១៨. តើកិច្ចការណាខ្លះក្នុងចំណោមកិច្ចការដូចតទៅ ដែលអ្នកគិតថាសហគមន៍ក្នុងស្រុកនៅតាមកន្លែងគោលដៅទេសចរណ៍ក្នុងតំបន់នេះគិតថាអាចអត់ឱនឬអាចទទួលយកបាន? (មនុស្សវ័យក្មេង=អាយុក្រោម១៨ឆ្នាំ) (ប្រសិនបើអ្នកមានចម្លើយច្រើនជាងមួយសូមផ្តល់យោបល់)

{ } កុមារ ឬមនុស្សវ័យក្មេងលក់វត្ថុអនុស្សាវរីយ៍

{ } កុមារ ឬមនុស្សវ័យក្មេងធ្វើការក្នុងរបររកស៊ីផ្លូវភេទ

{ } កុមារ ឬមនុស្សវ័យក្មេងដើរសុំទាន

{ } កុមារ ឬមនុស្សវ័យក្មេងសម្តែងសិល្បៈឲ្យភ្ញៀវទេសចរទេស្សនា

{ } កុមារ ឬមនុស្សវ័យក្មេងដើររើសសំរាម

{ } កុមារ ឬមនុស្សវ័យក្មេងធ្វើការតាមភោជនីយដ្ឋាន ឬសណ្ឋាគារ

{ } កុមារ ឬមនុស្សវ័យក្មេងធ្វើការជាមគ្គុទ្ទេសក៍ទេសចរ

{ } គ្រប់ចម្លើយខាងលើ

{ } គ្មានក្នុងជម្រើសខាងលើ

យោបល់ (តាមជម្រើស) ______________________

______________________________________________

១៩. តើផលប៉ះពាល់អ្វីដែលអ្នកជឿថាវិស័យទេសចរណ៍មានចំពោះបរិស្ថាន សហគមន៍ និងកុមារ និងមនុស្សវ័យក្មេង (អាយុក្រោម១៨ឆ្នាំ) ក្នុងស្រុក?

បរិស្ថានក្នុងស្រុក ៖

{ } ភាគច្រើនអវិជ្ជមាន

{ } គ្មានផលប៉ះពាល់

{ } ភាគច្រើនវិជ្ជមាន

សហគមន៍ក្នុងស្រុក ៖

{ } ភាគច្រើនអវិជ្ជមាន

{ } គ្មានផលប៉ះពាល់

{ } ភាគច្រើនវិជ្ជមាន

កុមារ និងមនុស្សវ័យក្មេងក្នុងស្រុក ៖

{ } ភាគច្រើនអវិជ្ជមាន

{ } គ្មានផលប៉ះពាល់

{ } ភាគច្រើនវិជ្ជមាន

២០. "នៅពេលខ្ញុំធ្វើដំណើរ ខ្ញុំយល់ថាខ្ញុំត្រូវចូលរួមទទួលខុសត្រូវចំពោះកុមារ និងមនុស្សវ័យក្មេងក្នុងស្រុក នៅតាមកន្លែងសាធារណៈ។"

{ } ប្រឆាំងទាំងស្រុង { } ប្រឆាំង

{ } អព្យាក្រឹត { } យល់ស្រប

{ }យល់ស្របទាំងស្រុង យោបល់ (តាមជម្រើស) ៖ ______

______________________________________________

______________________________________________

២១. "នៅពេលខ្ញុំធ្វើដំណើរ ខ្ញុំមានព័ត៌មានគ្រប់គ្រាន់ដើម្បីការពារកុមារ និងមនុស្សវ័យក្មេងក្នុងស្រុក នៅតាមកន្លែងសាធារណៈ។"

{ } ប្រឆាំងទាំងស្រុង { } ប្រឆាំង

{ } អព្យាក្រឹត { } យល់ស្រប

{ } យល់ស្របទាំងស្រុង យោបល់ (តាមជម្រើស) ៖ __

______________________________________________

______________________________________________

២២. តើអ្នកគិតថាអ្នកដំណើរ និងភ្ញៀវទេសចរអាចធ្វើអ្វីបានខ្លះដើម្បីជួយកុមារ និងមនុស្សវ័យក្មេងរក្សាសុវត្ថិភាពពីការរំលោភបំពាន/កេងប្រវ័ញ្ច?

______________________________________________

______________________________________________

២៣. ប្រសិនបើអាជីវកម្មមួយមានគោលនយោបាយ ការពារកុមារ តើចំណុចនេះនឹងជះឥទ្ធិពលជាវិជ្ជមានលើជម្រើសរបស់អ្នកក្នុងការទិញសេវាកម្ម/ទំនិញពីអាជីវកម្មនោះដែរឬទេ? (ប្រសិនបើអ្នកមានចម្លើយច្រើនជាងមួយ សូមផ្តល់យោបល់)

{ } បាទ/ចាស ប៉ុន្តែលុះត្រាតែតម្លៃសមរម្យដូចកន្លែងផ្សេង

{ } បាទ/ចាស បើទោះជាតម្លៃថ្លៃជាងកន្លែងផ្សេងក៏ដោយ

{ } បាទ/ចាស ប៉ុន្តែលុះត្រាតែខ្ញុំបានឃើញភស្តុតាងដែលគាំទ្រដល់គោលនយោបាយនោះ

{ } ចំណុចនេះនឹងមិនមានឥទ្ធិពលលើការសម្រេចចិត្តរបស់ខ្ញុំនោះទេ

{ } មិនដឹង យោបល់ ( តាមជម្រើស ) ៖ _______________

_______________________________________

២៤. តើអ្នកចង់ទទួលបានព័ត៌មានប្រភេទណាមុនពេលអ្នកធ្វើដំណើរ? ( ចូរគូសយកគ្រប់ចម្លើយដែលត្រឹមត្រូវ )

{ } ប្រាក់កម្រៃ និងលក្ខខណ្ឌការងារនៃប្រជាជនក្នុងស្រុកដែលធ្វើការក្នុងវិស័យទេសចរណ៍

{ } របៀបដែលភ្ញៀវទេសចរគាំទ្រដល់សេដ្ឋកិច្ចក្នុងស្រុក

{ } សារតានយោបាយនៃប្រទេស និងតំបន់នេះ

{ } ប្រពៃណីក្នុងស្រុក សម្លៀកបំពាក់ និងឥរិយាបថសមស្រប

{ } របៀបការពារកុមារ និងទប់ស្កាត់ការកេងប្រវ័ញ្ចលើកុមារនៅពេលធ្វើដំណើរ

{ } របៀបការពារបរិស្ថានក្នុងស្រុក និងកាត់បន្ថយការបំផ្លាញនៅពេលធ្វើដំណើរ

{ } គ្មានក្នុងជម្រើសខាងលើ

២៥. តើអ្នកចង់ទទួលព័ត៌មាននេះពីកន្លែងណា? ( ចូរគូសយកគ្រប់ចម្លើយដែលត្រឹមត្រូវ )

{ } ប្លុក និងគេហទំព័រស្តីពីវិស័យធ្វើដំណើរ និង ទេសចរណ៍

{ } ខិតប័ណ្ណផ្សព្វផ្សាយពីកន្លែងគោលដៅទេសចរណ៍របស់ខ្ញុំ

{ } ព័ត៌មានទទួលបាននៅពេលធ្វើដំណើរតាមយន្តហោះ ( ទស្សនាវដ្តី វីដេអូ -ល- )

{ } សៀវភៅមគ្គុទ្ទេសក៍

{ } ព្រលានយន្តហោះគោលដៅ និងមធ្យោបាយធ្វើដំណើរចុងក្រោយដទៃទៀត ( ឧ. ស្ថានីយរថភ្លើង ឡានក្រុង -ល- )

{ } មគ្គុទ្ទេសក៍ទេសចរនៅកន្លែងគោលដៅទេសចរណ៍របស់ខ្ញុំ

{ } ភ្នាក់ងារធ្វើដំណើរក្នុងប្រទេសរបស់ខ្ញុំ

{ } ផ្សេងទៀត ( សូមបញ្ជាក់ ) _______________

_______________________________________

_______________________________________

២៦. តើអ្នកស្នាក់នៅក្នុងប្រទេសណា? _______________

_______________________________________

២៧. បច្ចុប្បន្ន តើអ្នកស្ថិតក្នុងប្រទេសណា? _______________

_______________________________________

២៨. តើអ្នកមានភេទអ្វី?

{ } ស្រី

{ } ប្រុស

{ } មិនចង់ឆ្លើយ

សូមបញ្ជាក់មូលហេតុ ៖ _______________

_______________________________________

២៩. តើអ្នកកើតក្នុងឆ្នាំណា? ( សូមសរសេរលេខទាំង៤នៃឆ្នាំកំណើត ឧទាហរណ៍ ១៩៧៦ )

_______________________________________

_______________________________________

៣០. តើអ្នកឃើញការស្ទាបស្ទង់មតិនេះតាមណា?

{ } ប្រព័ន្ធផ្សព្វផ្សាយសង្គម ( Twitter, Facebook -ល- )

{ } អ៊ីមែលពីមិត្តភក្តិ/អ្នករួមការងារ

{ } គេហទំព័រ

{ } កាសែត Intrepid Express និងការបោះពុម្ពផ្សាយផ្សេងទៀតរបស់ក្រុមហ៊ុន Intrepid

{ } ផ្សេងទៀត ( សូមបញ្ជាក់ ) _______________

_______________________________________

_______________________________________

_______________________________________

_______________________________________

_______________________________________

_______________________________________

_______________________________________

_______________________________________

_______________________________________



www.childsafetourism.org

សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ៖ ទស្សនៈរបស់ភ្ញៀវទេសចរ

ISBN: ៩៧៨-០-៩៨៧៤៤៤១-៣-៤
រក្សាសិទ្ធិ © ឆ្នាំ២០១៣ ដោយអង្គការទស្សនៈពិភពលោកប្រចាំប្រទេសអូស្ត្រាលី

childsafetourism@wvi.org

Australian Aid

World Vision